

## មគ្គុទ្ទេសក៍ជាក់ស្តែងសម្រាប់សង្គមស៊ីវិល

# លំហសង្គមស៊ីវិល និងប្រព័ន្ធសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ស៊ុយអែត
Sverige

ឧបត្ថម្ភថវិកាដោយប្រទេសស៊ុយអែត

*000000000147*

ចែកជូនដោយឥតគិតថ្លៃ

# មាតិកា


១. អំពីមគ្គុទ្ទេសក៍នេះ.....1

២. តួអង្គសង្គមស៊ីវិល និងលំហសង្គមស៊ីវិល.....3

២.១ ប្រព័ន្ធសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ - ការពិនិត្យមួយគ្រួស.....5

៣. លក្ខខណ្ឌសម្រាប់ការងារសង្គមស៊ីវិលដោយសេរី និងឯករាជ្យ.....7

៣.១ បរិយាកាសនយោបាយ និងសាធារណៈអំណោយផល.....7

៣.២ បរិយាកាសបញ្ញត្តិកម្មដែលគាំទ្រ.....8

៣.៣ លំហូរព័ត៌មានដោយសេរី.....9

៣.៤ ការគាំទ្ររយៈពេលវែង និងធនធាន.....9

៣.៥ លំហាចែករំលែកសម្រាប់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការ.....9

៤. បញ្ហាប្រឈមដែលតួអង្គសង្គមស៊ីវិលជួបប្រទះ.....15

៤.១វិធានការផ្អែកលើច្បាប់ ឬ ផ្អែកលើវិធានដែលជាឧបសគ្គដល់ការងាររបស់សង្គមស៊ីវិល..15

៤.២ វិធានការតាមទំនើងចិត្ត.....16

៤.៣ ការយាយីរំខាន ការបំភិតបំភ័យ និងការសងសឹកក្រៅច្បាប់.....17

៥. តើខ្ញុំអាចធ្វើអ្វីបានខ្លះ? សូមងាកមកមើលអង្គការសហប្រជាជាតិវិញ.....23

៦. ធនធានឯកសារ.....30

៧. ទំនងទំនងជាមួយយើងខ្ញុំ.....31


ការតាំងចិត្ត និងសុច្ចរិតភាពរបស់តួអង្គសង្គមស៊ីវិល ផ្តល់ដល់ខ្ញុំ និងប្រហែលជាដល់លោកអ្នកផងដែរ នូវសេចក្តីគោរព និងអារម្មណ៍នៃការដឹងគុណយ៉ាងជ្រាលជ្រៅព្រមទាំងឆន្ទៈដើម្បីបន្តធ្វើការដើម្បីសេចក្តីថ្លៃថ្នូរ និងសិទ្ធិដែលមិនអាចដកហូតបានស្មើៗគ្នារបស់មនុស្សជាតិគ្រប់ៗរូប។

Zeid Ra'ad Al-Hussein,

ហ្សេដ រ៉ាអាដ អាលហ៊ូស្សេន

ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ខែតុលា ឆ្នាំ២០១៤


ឯកសារនេះ បោះពុម្ពផ្សាយក្រោយជំនួយថវិការបស់ប្រទេសស៊ុយអែត។
មាតិកា ឬខ្លឹមសារនៅក្នុងឯកសារនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមិនឆ្លុះ
បញ្ចាំងអំពីទស្សនៈ ឬការយល់ឃើញណាមួយរបស់ប្រទេសស៊ុយអែតឡើយ។



# ១. អំពីមគ្គុទ្ទេសក៍នេះ

សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ហើយនិងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ គឺជាសិទ្ធិមនុស្សដែលផ្ដល់លទ្ធភាពឲ្យមនុស្សគ្រប់រូបក្នុងការចែករំលែកគំនិត បង្កើតគំនិតថ្មីៗ ព្រមទាំងចូលរួមជាមួយអ្នកដទៃដើម្បីទាមទារសិទ្ធិរបស់ខ្លួន។ តាមរយៈការអនុវត្តសេរីភាពជាសាធារណៈទាំងនេះ យើងអាចធ្វើការសម្រេចចិត្តក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ អំពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់យើង។ តាមយៈសិទ្ធិទាំងនេះ ធ្វើឲ្យយើងអាចចូលរួមក្នុងសកម្មភាពប្រជាពលរដ្ឋ និងកសាងសង្គមប្រជាធិបតេយ្យ។ ការរឹតត្បិតលើសិទ្ធិ និងសេរីភាពទាំងនេះ ធ្វើឲ្យប៉ះពាល់ ដល់វឌ្ឍនភាពរួមរបស់យើង។

នេះគឺជាមគ្គុទ្ទេស៍ជាក់ស្ដែងលើកទី៦ ស្ដីពីសិទ្ធិមនុស្សរបស់ការិយាល័យ OHCHR សម្រាប់សង្គមស៊ីវិល ហើយគួរត្រូវបានមើលក្នុងបរិបទនៃ "ការពង្រីកលំហប្រជាធិបតេយ្យ" ដែលជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងៗបច្ចុប្បន្នរបស់ការិយាល័យ OHCHR។

មគ្គុទ្ទេសក៍នេះ គូសបញ្ជាក់អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការងាររបស់តួអង្គសង្គមស៊ីវិល (CSAs)។ មគ្គុទ្ទេស៍នេះ ចាប់ផ្តើមពីនិយមន័យផ្លូវការនៃពាក្យ "សង្គមស៊ីវិល" និង "លំហសង្គមស៊ីវិល"។ បន្ទាប់មកមគ្គុទ្ទេសក៍នេះ ផ្តល់នូវទិដ្ឋភាពរួមមួយអំពីលក្ខខណ្ឌ និងបរិយាកាសចាំបាច់សម្រាប់ការងាររបស់ សង្គមស៊ីវិលដោយសេរី និងឯករាជ្យ រាប់បញ្ចូលទាំងបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធសម្រាប់សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម និងក្នុងការជួបប្រជុំដោយសន្តិវិធី ព្រមទាំងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ។

មគ្គុទ្ទេសន៍នេះ ដាក់បញ្ចូលនូវឧទាហរណ៍មួយចំនួនអំពីរបៀបដែលរដ្ឋាភិបាលនិងតួអង្គសង្គមស៊ីវិល បានធ្វើការងាររួមគ្នា បង្កើតលំហសម្រាប់សង្គមស៊ីវិល ក្នុងការអនុវត្តការងាររបស់ខ្លួនដើម្បីឈានទៅសម្រេច សិទ្ធិមនុស្សទាំងអស់ (សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) សម្រាប់មនុស្ស គ្រប់រូប។ ឧបសគ្គ និងការកម្រិតដែនកំណត់ទៅលើការងាររបស់សង្គមស៊ីវិល ត្រូវបានរកឃើញ រាប់បញ្ចូលទាំងការយាយីរំខានការបំភិតបំភ័យ និងការសងសឹកទៅលើតួអង្គសង្គមស៊ីវិល។ មគ្គុទ្ទេសក៍នេះ ស្នើឲ្យតួអង្គសង្គមស៊ីវិលប្រើប្រាស់ប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីលើកស្ទួយ និងការពារដល់លំហសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន។ ធនធាន និងព័ត៌មានទំនាក់ទំនង លម្អិត ត្រូវបានផ្តល់ជូននៅចុងបញ្ចប់នៃមគ្គុទ្ទេសក៍នេះ។

មគ្គុទ្ទេសក៍នេះមានគោលបំណងចម្បងជួយដល់តួអង្គស៊ីវិលដែលមិនទាន់បានដឹងអំពីប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ ការបង្កើតមគ្គុទ្ទេសក៍នេះ មានដាក់បញ្ចូលតាំងពីដើមដំបូងនូវមតិយោបល់របស់តួអង្គសង្គមស៊ីវិលផ្សេងៗ ។

# ២. តួអង្គសង្គមស៊ីវិល និងលំហសង្គមស៊ីវិល

"ប្រសិនជាមេដឹកនាំមិនស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋខ្លួន ពួកគេនឹងឮពីពួកគេ នៅតាមដងផ្លូវ នៅទីលាននានា ឬនៅក្នុងសមរភូមិដូចដែលយើង តែងឃើញជាញឹកញាប់មកហើយ។ មានវិធីប្រសើរជាងនេះ។ ការចូលរួមកាន់តែច្រើន។ ប្រជាធិបតេយ្យកាន់តែច្រើន។ ការចូលរួមនិងការបើកចំហកាន់តែច្រើន។ នោះ មានន័យថា លំហជាអតិបរមាសម្រាប់សង្គមស៊ីវិល"។

សន្ទរកថារបស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឯព្រឹត្តិការណ៍ថ្នាក់កំពូល ស្តីពីការគាំទ្រសង្គមស៊ីវិល ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

មគ្គុទ្ទេសក៍នេះ កំណត់និយមន័យនៃតួអង្គសង្គមស៊ីវិល (CSAs) ថាជាបុគ្គល និងក្រុមដែលធ្វើការងារ ដោយស្ម័គ្រចិត្ត ក្នុងរូបភាពជាសកម្មភាព និងការចូលរួមជាសាធារណៈជុំវិញផលប្រយោជន៍ គោលបំណង ឬតម្លៃរួម ដែលស្របនឹងគោលដៅរបស់អង្គការសហប្រជាជាតិ៖ ការរក្សាសន្តិភាព និងសន្តិសុខ ការសម្រេច បាននូវការអភិវឌ្ឍ និងការលើកកម្ពស់ និងការគោរពសិទ្ធិមនុស្ស។

ការងាររបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវិតរស់នៅរបស់យើង ត្រូវបានចាក់ ឫសនៅក្នុងការគោរពសិទ្ធិមនុស្ស។ ហើយទោះបីជាច្បាស់ក្តី ឬមិនច្បាស់លាស់ក្តី តាមរយៈខ្លឹមសារ ឬចរិត លក្ខណៈនៃការងាររបស់ពួកគេ តួអង្គសង្គមស៊ីវិល ដូចបានកំណត់និយមន័យខាងលើ ធ្វើការដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស។

តួអង្គសង្គមស៊ីវិលលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិផ្សេងៗ ជួយសហគមន៍នៅក្នុងការបង្ហាញកង្វល់ បង្កើតយុទ្ធសាស្ត្រ ជម្រុញឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងច្បាប់ និងជំរុញឲ្យមានគណនេយ្យភាព។ តួអង្គសង្គមស៊ីវិលប្រមូល និងពាំនាំមតិយោបល់របស់សហគមន៍ ដើម្បីអាចឲ្យគេយកទៅពិនិត្យពិចារណា ឲ្យបានពេញលេញថែមទៀត នៅក្នុងការធ្វើសេចក្តីសម្រេចស្តីពីគោលនយោបាយសាធារណៈ។ តួអង្គសង្គមស៊ីវិល បំពេញសេវាបន្ថែមផងដែរតាមរយៈការងាផ្សេងៗដល់ប្រជាពលរដ្ឋដែលប្រឈមនឹងហានិភ័យ និងដែលងាយរងគ្រោះ ។

"មនុស្សគ្រប់រូបមានសិទ្ធិ ទោះបីជាលក្ខណៈបុគ្គលក្តី ឬដោយការចូលរួមជាមួយអ្នកដទៃក្តី ក្នុងការលើកស្ទួយ និងជួយការពារ និងធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននៅថ្នាក់ជាតិ និងអន្តរជាតិ"។ (មាត្រា១ បន្ថែមការសង្កត់ធ្ងន់)។

សេចក្តីប្រកាសស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការនៃសង្គម ដើម្បីលើកកម្ពស់និងការពារដល់សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដែលគេទទួលស្គាល់ជាសកល (សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ៥៣/១៤៤) ដែលគេហៅជាទូទៅថាសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។

ឧទាហរណ៍ តួអង្គសង្គមស៊ីវិល រួមមាន ៖[1]

- អ្នកការពារសិទ្ធិមនុស្ស រួមទាំងសកម្មជនតាមអនឡាញ
- អង្គការសិទ្ធិមនុស្ស (NGOs សមាគម ក្រុមគាំទ្រជនរងគ្រោះ)
- សម្ព័ន្ធភាពនិងបណ្តាញ (ឧទាហរណ៍ ស្តីពីសិទ្ធិស្ត្រី សិទ្ធិកុមារ ឬបញ្ហាបរិស្ថាន សិទ្ធិដីធ្លី មនុស្សស្រលាញ់ភេទដូចគ្នា(LGBT) ។ល។)
- ជនមានពិការភាព និងអង្គការតំណាងរបស់ពួកគេ
- ក្រុមមានមូលដ្ឋាននៅតាមសហគមន៍ (ជនជាតិដើមភាគតិច ជនជាតិភាគតិច សហគមន៍ជនបទ)
- ក្រុមសាសនា (ព្រះវិហារគ្រិស្ត ក្រុមសាសនាផ្សេងៗ)
- សហជីព (សហជីពកម្មករ ក៏ដូចជា សមាគមវិជ្ជាជីវៈផ្សេងៗ ដូចជាសមាគមអ្នកសារព័ត៌មាន សមាគមចៅក្រម និងសមាគមមេធាវី និងគណៈមេធាវី សមាគមចៅក្រម សហជីពនិស្សិត)
- ចលនាសង្គម (ចលនាសន្តិភាព ចលនានិស្សិត ចលនាគាំទ្រលទ្ធិប្រជាធិបតេយ្យ)
- អ្នកវិជ្ជាជីវៈដែលរួមចំណែកដោយផ្ទាល់ដល់ការទទួលបានសិទ្ធិមនុស្ស (ឧទា. បុគ្គលិកផ្នែកមនុស្សធម៌ មេធាវី គ្រូពេទ្យ និងបុគ្គលិកសុខាភិបាល)
- សាច់ញាតិ និងសមាគមជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស ព្រមទាំង
- ស្ថាប័នសាធារណៈដែលអនុវត្តសកម្មភាពផ្សេងៗ សំដៅលើកកម្ពស់សិទ្ធិមនុស្ស (សាលារៀន សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ)។

តួអង្គសង្គមស៊ីវិល ដែលសកម្មក្នុងការខិតខំជួយដោះស្រាយបញ្ហា និងលើយកបញ្ហារ ដែលមានសារៈសំខាន់សម្រាប់សង្គម ដូចជា៖

- ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ អំពើពុករលួយ និងវិសមភាពសេដ្ឋកិច្ច
- ការឆ្លើយតបទៅនឹងវិបត្តិមនុស្សធម៌ រួមទាំងជម្លោះប្រដាប់អាវុធ
- ការលើកកម្ពស់នីតិរដ្ឋ និងគណនេយ្យភាព
- ការលើកកម្ពស់សេរីភាពសាធារណៈ
- ការតស៊ូមតិឲ្យមានតម្លាភាពក្នុងថវិការដ្ឋ
- ការការពារបរិស្ថាន
- ការធ្វើឲ្យទទួលបានសិទ្ធិក្នុងការអភិវឌ្ឍ
- ការផ្តល់សិទ្ធិអំណាចដល់បុគ្គលដែលស្ថិតនៅក្នុងក្រុមជនជាតិភាគតិចនិងក្រុមដទៃទៀត ដែលមានហានិភ័យ
- ការប្រយុទ្ធប្រឆាំងនឹងការរើសអើងតាមទម្រង់ណាមួយ

[1] ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ កូនសៀវភៅព័ត៌មានសម្រាប់សង្គមស៊ីវិល OHCHR, 2008, p. vii.

- ការគាំទ្រដល់ការបង្ការបទល្មើស
- ការលើកកម្ពស់ការទទួលខុសត្រូវសង្គម និងគណនេយ្យភាពរបស់សាជីវកម្ម
- ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស
- ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី
- ការប្រយុទ្ធប្រឆាំងនឹងពាក្យសំដីដែលនាំឲ្យមានការស្អប់ខ្ពើម
- ការផ្តល់សិទ្ធិអំណាចដល់យុវជន
- ការជំរុញឲ្យមានយុត្តិធម៌ សង្គម និងការការពារអ្នកប្រើប្រាស់
- ការផ្តល់សេវាសង្គម

តួអង្គសង្គមស៊ីវិល ធ្វើសកម្មភាពនៅគ្រប់ជាន់ថ្នាក់៖ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និង ថ្នាក់អន្តរជាតិ។

លំហសង្គមស៊ីវិល គឺជាទីកន្លែងដែលតួអង្គសង្គមស៊ីវិលត្រូវតែមាននៅក្នុងសង្គម បរិយាកាស និងក្របខ័ណ្ឌដែលក្នុងនោះសង្គមស៊ីវិលប្រតិបត្តិការ និងទំនាក់ទំនងក្នុងចំណោមតួអង្គសង្គមស៊ីវិលវិស័យឯកជន និងសាធារណជនទូទៅ។

## ២.១ ប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ - ការពិនិត្យមួយត្រួស

ទន្ទឹងនឹងការធានាសន្តិភាព និងសន្តិសុខ និងការធ្វើការឲ្យសម្រេចបាននូវការអភិវឌ្ឍទូទាំងពិភពលោកការលើកកម្ពស់ និងការពារសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបីរបស់អង្គការសហប្រជាជាតិ។ សរស្តម្ភនេះ បានកំណត់យ៉ាងច្បាស់នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។

អង្គការសហប្រជាជាតិ ខិតខំប្រឹងប្រែងលើកកម្ពស់និងការពារសិទ្ធិមនុស្សតាមមធ្យោបាយជាមូលដ្ឋាន ចំនួនបីគឺ ៖

១. ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (OHCHR) គឺជាអង្គការនាំមុខនៅក្នុងអង្គការសហប្រជាជាតិ ដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស។ ការិយាល័យនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារឯកទេសនានារបស់អង្គការសហប្រជាជាតិ ថវិកា និងកម្មវិធីនានា (មានជាអាទិ៍ អង្គការសុខភាពពិភពលោក ទីភ្នាក់ងារអ.ស.ប ទទួលបន្ទុកជនភៀសខ្លួន អង្គការយូនីសេហ្វ អង្គការពលកម្មអន្តរជាតិ អង្គការយូណេស្កូ។ល។) ដើម្បីបង្កើនជាអតិបរមានូវប្រសិទ្ធភាពការងារសិទ្ធិមនុស្ស។

២. សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ (កតិកាសញ្ញា និងអនុសញ្ញា) បង្កើតឲ្យមានក្រុមអ្នកជំនាញឯករាជ្យ ឬស្ថាប័នសន្ធិសញ្ញា ដើម្បីពិនិត្យពិចារណាយ៉ាងទៀងទាត់ និងតាមកាលកំណត់ទៅលើការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសទាំងឡាយ។

៣. ស្ថាប័នអន្តររដ្ឋាភិបាល ឬសភាទាំងឡាយដែលមានសមាសភាពរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងដើម្បីពិភាក្សាបញ្ហា និងស្ថានភាពសិទ្ធិមនុស្ស។ ស្ថាប័នអន្តររដ្ឋាភិបាលចម្បងមួយសម្រាប់គោលបំណងនេះ គឺក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលការងាររបស់ខ្លួនត្រូវបានជួយជ្រោមជ្រែង ដោយអ្នកជំនាញឯករាជ្យដែលហៅថា នីតិវិធីពិសេស និងយន្តការមួយដែលគេហៅថា យន្តការត្រួតពិនិត្យ របាយការណ៍តាមកាលកំណត់ជាសកលដែលជាយន្តការមួយក្នុងចំណោមយន្តការដទៃផ្សេងទៀត។

ផ្នែកទាំងបីនេះ គឺឯករាជ្យដាច់ពីគ្នា ប៉ុន្តែបំពេញឲ្យគ្នាទៅវិញទៅមក។

ការពន្យល់លម្អិតអំពីអាណត្តិការងារ និងយន្តការទាំងនេះ អាចស្វែងរកនៅក្នុងការធ្វើការងារជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ៖ កូនសៀវភៅសម្រាប់សង្គមស៊ីវិល( សូមមើលផ្នែកទី៦ ចំនុច ធនធាន )។ កូនសៀវភៅនេះ មានផ្សព្វផ្សាយជាប្រាំមួយភាសាផ្លូវការរបស់អ.ស.ប និងមាននៅក្នុងប្រព័ន្ធព័ត៌មាន Digital Accessible Information System (DAISY) ជាស៊ីឌី (CD Rom) ជាភាសាបារាំង និងអង់គ្លេសសម្រាប់បុគ្គលដែលមានពិការភាពភ្នែក និងពិការអំណាន។

ការងាររបស់យន្តការសិទ្ធិមនុស្ស អ.ស.ប ដំណើការទៅបានតាមរយៈការចូលរួមពីតួអង្គសង្គមស៊ីវិល។ នៅថ្នាក់អន្តរជាតិ សង្គមស៊ីវិលចូលរួមចំណែកជាជំនាញ លើកកម្ពស់ការយល់ដឹង និងការឃ្លាំមើល និងការធ្វើរបាយការណ៍អំពីបញ្ហា និងការរំលោភសិទ្ធិមនុស្ស។ តួអង្គសង្គមស៊ីវិល ជួយបង្កើតឲ្យមានស្តង់ដារ យន្តការ និងស្ថាប័នសិទ្ធិមនុស្សថ្មីៗ និងកៀងគរធនធាន និងការគាំទ្រជាសាធារណៈសម្រាប់បញ្ហាសិទ្ធិមនុស្ស។

### គំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិស្តីពីសង្គមស៊ីវិល

ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប បានអនុម័តសេចក្តីសម្រេចដ៏មានសារៈសំខាន់ជាច្រើន សម្រាប់សង្គមស៊ីវិល ដូចជា សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសមាគម និងការជួបប្រជុំដោយសន្តិវិធី សេរីភាពចាកផុតពីការបំភិតបំភ័យ និងការសងសឹក និងអ្នកការពារសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ ក្រុមប្រឹក្សា បានអនុម័តសេចក្តីសម្រេចលេខ២៧/៣១ និង២៤/២១ ស្តីពីលំហសង្គមស៊ីវិល ទទួលស្គាល់ "សារៈសំខាន់ ជាសារវ័ននៃការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិលនៅគ្រប់កម្រិត ក្នុងដំណើរការអភិបាលកិច្ច និងនៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ រួមបញ្ចូលទាំងតាមរយៈតម្លាភាព និងគណនេយ្យភាពនៅគ្រប់ជាន់ថ្នាក់ ដែលចាំបាច់មិនអាចខ្វះបាន ដើម្បីកសាងសង្គមប្រកបដោយសន្តិភាព វឌ្ឍនភាព និងប្រជាធិបតេយ្យ"។

# ៣. លក្ខខណ្ឌសម្រាប់ការងារសង្គមស៊ីវិលដោយសេរី និងឯករាជ្យ

"សង្គមស៊ីវិលមួយដែលសេរី និងឯករាជ្យ គឺជាមូលដ្ឋានគ្រឹះសម្រាប់អភិបាលកិច្ចល្អ និងដែលឆ្លើយតបនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកល"។

សារវីដេអូរបស់លោក បាន គីមូន អគ្គលេខាធិការ ទៅកាន់សម័យប្រជុំលើកទីម្ភៃប្រាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ខែមីនា ឆ្នាំ២០១៤

កាតព្វកិច្ចច្បាប់អន្តរជាតិរបស់រដ្ឋ តម្រូវឲ្យរដ្ឋបង្កើតលក្ខខណ្ឌ - ខាងសេដ្ឋកិច្ច នយោបាយសង្គម វប្បធម៌ ច្បាប់ដែលគាំទ្រយ៉ាងសកម្មភាពដល់លទ្ធភាព និងសមត្ថភាពរបស់បុគ្គល ជាឯកត្តបុគ្គល ឬដោយចូលរួមជាមួយអ្នកដទៃ ដើម្បីចូលរួមក្នុងសកម្មភាពពលរដ្ឋ។

គោលការណ៍សិទ្ធិមនុស្សដែលបង្កើតទំនាក់ទំនងរវាងអាជ្ញាធរសាធារណៈ និងតួអង្គសង្គមស៊ីវិលគឺ៖

- **ការចូលរួម**-តួនាទីរបស់សង្គមស៊ីវិលនៅក្នុងសង្គមត្រូវបានទទួលស្គាល់ហើយតួអង្គសង្គមស៊ីវិលមានសេរីភាពក្នុងការធ្វើសកម្មភាពដោយឯករាជ្យ និងមុខងារតស៊ូមតិខុសពីមុខងាររបស់អាជ្ញាធរសាធារណៈ ។
- **ភាពគ្មានការរើសអើង**-តួអង្គសង្គមស៊ីវិលទាំងអស់ត្រូវបានអញ្ជើញ និងត្រូវបានផ្តល់លទ្ធភាពចូលរួមក្នុងជីវភាពសាធារណៈដោយគ្មានការរើសអើងណាមួយឡើយ។
- **សេចក្តីថ្លៃថ្នូរ**-អាជ្ញាធរសាធារណៈ និងតួអង្គសង្គមស៊ីវិល មានគោលបំណងរួមគ្នាក្នុងការធ្វើឲ្យប្រសើរឡើងដល់ជីវិតរស់នៅ ទន្ទឹមនឹងបំពេញតួនាទីផ្សេងៗ គ្នា។ ការគោរពគ្នាទៅវិញទៅមកគឺមានសារៈសំខាន់ណាស់ចំពោះទំនាក់ទំនងនេះ។
- **តម្លាភាព និងគណនេយ្យភាព**-ការធ្វើសកម្មភាពដើម្បីផលប្រយោជន៍សាធារណៈ តម្រូវឲ្យមានការបើកចំហ ការទទួលខុសត្រូវ ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពពីមន្ត្រីសាធារណៈ។ វាតម្រូវឲ្យមានផងដែរ នូវតម្លាភាព និងគណនេយ្យភាពពីតួអង្គសង្គមស៊ីវិលចំពោះគ្នាទៅវិញទៅមក និងចំពោះសាធារណជន។

លក្ខខណ្ឌសំខាន់ៗដែលនាំមកនូវការអនុវត្តល្អ[2] ៖

## ៣.១ បរិយាកាសនយោបាយនិងសាធារណៈអំណោយផល

គឺជាបរិយាកាសនយោបាយ និងសាធារណៈដែលផ្តល់តម្លៃ និងលើកទឹកចិត្តដល់ការរួមចំណែកពី

---

[2] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស ធាតុផ្សំនៃបរិយាកាសដែលមានសុវត្ថិភាពនិងអំណោយផលសម្រាប់អ្នកការពារសិទ្ធិមនុស្ស, A/HRC/25/55.

ពលរដ្ឋ។ តាមការអនុវត្តជាក់ស្តែង ស្ថាប័ន និងមន្ត្រីសាធារណៈត្រូវឆ្លើយតបទៅនឹងតួអង្គសង្គមស៊ីវិល នៅក្នុងអន្តរកម្មជាធម្មតារបស់ពួកគេ។

**ទុយនេស៊ី**-សង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងប្រទេសទុយនេស៊ីថ្មីដោយការចូលរួមនៅក្នុងការបង្កើតច្បាប់ និងគោលនយោបាយថ្មីដ៏មានសារសំខាន់សម្រាប់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។ អង្គការសង្គម ស៊ីវិលត្រូវបានពិគ្រោះយោបល់អំពីគំនិតផ្តួចផ្តើមដំបូងអំឡុងពេលអន្តរកាលប្រជាធិបតេយ្យ ដូចជា ក្រឹត្យច្បាប់ស្តីពីការលើកលែងទោសជាទូទៅដល់អ្នកទោសមនសិកា ព្រមទាំងច្បាប់ស្តីពីការចូលជាសមាជិកសន្ធិសញ្ញា អន្តរជាតិចំនួនបួន (អនុសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ពិធីសារ បន្ថែម ទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងប្រព្រឹត្តិកម្ម ឬការដាក់ទណ្ឌកម្មបែបឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក និងលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ)។ អង្គការសង្គមស៊ីវិលបានចូលរួមបង្កើតស្ថាប័នប្រជាធិបតេយ្យជាសារវ័ន្តដែលបានប្រកាសឲ្យប្រើប្រាស់ច្បាប់បោះឆ្នោតថ្មីមួយ និងបានអនុម័តច្បាប់ថ្មីមួយស្តីពីសេរីភាពក្នុងការ បង្កើតសមាគម ដែលបានដាក់បញ្ចូលបទប្បញ្ញត្តិមួយស្តីពីការផ្តល់ពីថវិការដ្ឋសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការផ្តល់ថវិកាពីក្រៅប្រទេស។ សមាគមរាប់ពាន់ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសទុយនេស៊ី ចាប់តាំងពីការអនុម័តច្បាប់តាំងខែកញ្ញា ឆ្នាំ២០១១ មក។ តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការបោះឆ្នោតឆ្នាំ២០១១ ដែលជាការបោះឆ្នោតប្រកបដោយប្រជាធិបតេយ្យ និងតម្លាភាពដំបូងបំផុតនៅក្នុងប្រទេសទុយនេស៊ី គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់។ ជាលើកដំបូងបំផុត ដោយមានជំនួយពីសហគមន៍អន្តរជាតិ សកម្មជនសង្គមស៊ីវិលជាង១០.០០០នាក់ ត្រូវបានប្រមូលផ្តុំគ្នាឃ្លាំមើលការបោះឆ្នោតសភាធម្មនុញ្ញ។ ជាពិសេស អង្គការស្ត្រី បានតស៊ូ មតិទាមទារឲ្យមានការដាក់បញ្ចូលសមភាពពេញលេញរវាងបុរសនិងស្ត្រីទៅក្នុងអត្ថបទនៃសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មីដែលត្រូវបានអនុម័តដោយសម្លេងភាគច្រើនលើសលុបនៃសភាធម្មនុញ្ញក្នុងខែមករា ឆ្នាំ២០១៤។

សេចក្តីសង្ខេបនៃកិច្ចពិភាក្សាគណៈវាគ្មិននៃក្រុមប្រឹក្សាសិទ្ធិមនុស្សអំពីសារៈសំខាន់នៃការលើកកម្ពស់និងការការពារលំហសង្គមស៊ីវិល A/HRC/27/33។

## ៣.២ ក្របខ័ណ្ឌបញ្ញត្តិកម្មដែលគាំទ្រ

ច្បាប់ វិធានរដ្ឋបាល និងការអនុវត្តជាក់ស្តែង គឺត្រូវស្របតាមស្តង់ដារអន្តរជាតិ និងធានាការពារសុវត្ថិភាពសកម្មភាពរបស់សង្គមស៊ីវិល។ ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌សម្រាប់តួអង្គសង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ និងមានប្រសិទ្ធភាព ព្រមទាំងការប្រើប្រាស់យន្តការសិទ្ធិមនុស្សអន្តរជាតិ គឺជាកត្តាចាំបាច់ចំពោះក្របខ័ណ្ឌនេះ។ ច្បាប់ និងគោលនយោបាយសមស្រប មានសារៈសំខាន់បំផុត ប៉ុន្តែវានឹងគ្មានប្រសិទ្ធភាពនោះទេ ប្រសិនបើមិនត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវទេនោះ។

**នៅក្នុងប្រទេសស្លូវេនី** សិទ្ធិសេរីភាពខាងសមាគម ការពារសមាគមទាំងអស់ រាប់បញ្ចូលទាំងសមាគមដែលមិនបានចុះបញ្ជិកាផងដែរ ហើយបានចែងថាបុគ្គលដែលពាក់ព័ន្ធនៅក្នុងសមាគមដែលមិនបានចុះបញ្ជីគួរតែមាន សេរីភាពក្នុងការអនុវត្តសកម្មភាពផ្សេងៗ រួមទាំងសកម្មភាពរៀបចំ និងចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធីផងដែរ។

របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីនិងខាងសមាគម A/HRC/20/27.

នៅប្រទេសលីបង់ និងម៉ូរ៉ូក្កូ ច្បាប់ មិនតម្រូវឲ្យមានការអនុញ្ញាតពីអាជ្ញាធរ មុនពេលសង្គមស៊ីវិលទទួលបានការផ្តល់ថវិកាពីក្នុងប្រទេស និងក្រៅប្រទេស។

របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម A/HRC/20/27.

## ៣.៣ លំហរព័ត៌មានដោយសេរី

ការទទួលបានដោយសេរីនូវគំនិត ទិន្នន័យ របាយការណ៍ គំនិតផ្តួចផ្តើម និងការសម្រេចចិត្តផ្សេងៗ ដើម្បីផ្តល់លទ្ធភាពដល់តួអង្គសង្គមស៊ីវិលឲ្យបានយល់ដឹង និងជ្រួតជ្រាបអំពីបញ្ហានានា សំដែងក្តីកង្វល់ ចូលរួមប្រកបដោយការស្ថាបនា និងរួមចំណែកក្នុងដំណោះស្រាយ។

## ៣.៤ ការគាំទ្ររយៈពេលវែង និងធនធាន

វិធានការដើម្បីកសាងសមត្ថភាពសម្រាប់សម្លេងដែលងាយរងគ្រោះ និងធានាដល់ការប្រើប្រាស់ធនធាន ទីកន្លែងប្រជុំ និងបច្ចេកវិទ្យាដល់គ្រប់តួអង្គសង្គមស៊ីវិលទាំងអស់។

**នៅក្នុងប្រទេសក្រូអាធី** រដ្ឋាភិបាលបានអនុម័តក្រមប្រតិបត្តិល្អ ស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ជំនួយឥតសំណងសម្រាប់កម្មវិធី និងគម្រោងរបស់សមាគម (២០០៧) ដែលដាក់ចេញនូវវិធាន និងនីតិវិធី ជាមូលដ្ឋានប្រកបដោយតម្លាភាពសម្រាប់អាជ្ញាធរសាធារណៈនៅគ្រប់កម្រិតថ្នាក់នៃរដ្ឋាភិបាល នៅក្នុងការបែងចែកជំនួយឥតសំណងសាធារណៈ។

មជ្ឈមណ្ឌលអឺរ៉ុបសម្រាប់ច្បាប់មិនគិតកម្រៃ (ECNL) ការផ្តល់ថវិកាសាធារណៈសម្រាប់អង្គការសង្គមស៊ីវិល៖ ការអនុវត្តល្អនៅក្នុងសហភាពអឺរ៉ុប និងបាល់កង់ខាងលិច ឆ្នាំ២០១១។

## ៣.៥ លំហរួមគ្នាសម្រាប់កិច្ចសន្ទនា និងសហប្រតិបត្តិការ

ធានាឲ្យមានកន្លែងសម្រាប់សង្គមស៊ីវិល នៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។

**នៅប្រទេសម៉ាល់ឌីវ** ក្នុងឆ្នាំ២០១៤ រដ្ឋាភិបាលបានគាំទ្រដល់វេទិកាមួយដែលមានរយៈពេលប្រាំថ្ងៃ សម្រាប់អ្នកតស៊ូមតិសិទ្ធិស្ត្រី ដើម្បីចែករំលែក និងពិភាក្សាបទពិសោធន៍ថ្នាក់តំបន់អំពីការសម្រេចបាន វិសមភាពយេនឌ័រ នៅក្នុងក្របខ័ណ្ឌអ៊ីស្លាមរួមជាមួយអង្គការក្រៅរដ្ឋាភិបាលថ្នាក់តំបន់ និងអង្គការអន្តរជាតិ។

**នៅប្រទេសម៉ិកស៊ីកូ** ច្បាប់ឆ្នាំ២០១២ សម្រាប់ការពារអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន បានចែងឲ្យមានយន្តការជាតិមួយដើម្បីដោះស្រាយការគំរាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្សនិងអ្នកសារព័ត៌មាន។ ច្បាប់នេះ ត្រូវបានព្រាងឡើងដោយមានការចូលរួមពីតួអង្គសង្គមស៊ីវិល និងសភា ហើយត្រូវបានគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនិងអង្គការផ្សេងៗក៏ដូចជា OHCHR ប្រចាំនៅប្រទេសម៉ិកស៊ីកូ។

**នៅប្រទេសនេប៉ាល់** នៅក្នុងឆ្នាំ២០១០ ច្បាប់ស្តីពីការរើសអើងដោយផ្អែកលើវណ្ណៈសង្គម (Caste) និងវណ្ណៈខ្ពស់បំផុត(Caste-based discrimination and Untouchability) ត្រូវបានព្រាងឡើងដោយមានការចូលរួមពី សង្គមស៊ីវិល គណៈកម្មការដាលីតជាតិ (National Dalit Commission) និងការិយាល័យប្រចាំប្រទេសរបស់ OHCHR។ ច្បាប់នេះត្រូវអនុម័តក្នុងខែឧសភាឆ្នាំ២០១១។

**នៅប្រទេសញូវស៊ែលឡែន** ក្នុងឆ្នាំ២០១១ ច្បាប់ស្តីពីពិការភាព ត្រូវបានព្រាងឡើងដោយមានការចូលរួមពីសមាគមជនពិការ។

របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំនិងបង្កើតសមាគមA/HRC/20/27.

**នៅប្រទេសវ៉ានូអាទូ**(Vanuatu) នៅក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការ UPR ដែលអនុប្រធានគណៈកម្មាធិការនេះ គឺជាតំណាងមកពីសមាគមអង្គការមិនមែនរដ្ឋាភិបាលវ៉ានូអាទូ។ បន្ថែមពីលើនេះ សង្គមស៊ីវិល មានតំណាងនៅក្នុងគណៈកម្មាធិការសិទ្ធិមនុស្សជាតិ(NHRC) ដែលជាស្ថាប័នមានអាណត្តិសម្របសម្រួលកាតព្វកិច្ចសរសេររបាយការណ៍អំពីសិទ្ធិមនុស្សរបស់ប្រទេសវ៉ានូអាទូ និងនៅក្នុងការបង្កើតស្ថាប័នសិទ្ធិ មនុស្សជាតិ។ ក្នុងឆ្នាំ២០១៣ អង្គការដែលធ្វើការជាមួយជនមានពិការភាពត្រូវបានពិគ្រោះយោបល់យ៉ាង ទូលំទូលាយនៅក្នុងការរៀបចំសេចក្តីព្រាងរបាយការណ៍ដើម្បីដាក់ជូនគណៈកម្មាធិការស្តីពីសិទ្ធិជនពិការ។

## ស្តង់ដារច្បាប់អន្តរជាតិទាក់ទងទៅនឹងការងាររបស់សង្គមស៊ីវិល

បរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់ការងាររបស់សង្គមស៊ីវិល ត្រូវតែគាំទ្រដោយក្របខ័ណ្ឌច្បាប់ជាតិដ៏រឹងមាំមួយដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម ក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ គឺជាសិទ្ធិដែលផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋធ្វើការគៀងគរ ដើម្បីឲ្យមានការផ្លាស់ប្តូរ វិជ្ជមាន។ មនុស្សគ្រប់រូប ជាឯកត្តបុគ្គលក្តី ឬចូលរួមជាមួយអ្នកដទៃក្តី គួរតែទទួលបានសិទ្ធិទាំងនេះ។ សិទ្ធិទាំងនេះគឺជាសិទ្ធិសារវ័ន្ត សម្រាប់សកម្មភាពរបស់ពលរដ្ឋ។

លិខិតុបករណ៍អន្តរជាតិសំខាន់ៗស្តីពីសិទ្ធិមនុស្សភាគច្រើន ដាក់បញ្ចូលបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធ ដោយផ្ទាល់ទៅនឹងការការពារសេរីភាពសាធារណៈ ហើយលិខិតុបករណ៍ទាំងនេះនិយាយសំដៅទៅលើគោលការណ៍នៃការមិនរើសអើង។

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា១៩, ២០, ២១)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ផ្តល់សិទ្ធិសេរីភាពក្នុងការបញ្ចេញទស្សនៈនិងខាងបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសមាគម និងការចូលរួមក្នុងជីវភាពសាធារណៈ (មាត្រា១៩, ២១, ២២, ២៥)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ផ្តល់សិទ្ធិក្នុងការបង្កើត ឬចូលរួមក្នុងសហជីព និងចូលរួមក្នុងជីវភាពវប្បធម៌ (មាត្រា ៨, ១៥)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទផ្តល់សិទ្ធិដល់ស្ត្រីក្នុងការចូល រួមក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌ (មាត្រា ៣)
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងជាតិសាសន៍ ហាមឃាត់ការរើសអើងទាក់ទងទៅនឹងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម និងការអនុវត្តកិច្ចការសាធារណៈ(មាត្រា៥)
- អនុសញ្ញាស្តីពីសិទ្ធិកុមារផ្តល់សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម និងក្នុងការជួបប្រជុំដោយសន្តិវិធី (មាត្រា១៣, ១៥)
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ ធានាការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញទស្សនៈ និងក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន ការចូលរួមនៅក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈ ក៏ដូចជានៅក្នុងជីវភាពវប្បធម៌ (មាត្រា២១, ២៩ និង៣០)
- អនុសញ្ញាអន្តរជាតិសម្រាប់ការពារជនគ្រប់រូប ពីការបាត់ខ្លួនដោយបង្ខំ ផ្តល់សិទ្ធិបង្កើតនិងចូលរួមដោយសេរីក្នុងអង្គការ និងសមាគមនានាដែលពាក់ព័ន្ធនឹងការប៉ុនប៉ងបង្កើតកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ និងវាសនារបស់បុគ្គលដែលបាត់ខ្លួន និងដើម្បីជួយជនរងគ្រោះដែលបាត់ខ្លួនដោយបង្ខំ (មាត្រា ២៤)និង
- អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់កម្មករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ផ្តល់សិទ្ធិបង្កើតសមាគម (មាត្រា ២៦)។

សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម និងក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ គឺជាយានមួយសម្រាប់ការអនុវត្តសិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គមដទៃទៀត។ សេរីភាពទាំងនេះ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី បុរស និងកុមារ ដើម្បីចូលរួមក្នុងសកម្មភាពនានាក្នុងគោលបំណងនាំមកនូវការផ្លាស់ប្តូរក្នុងសង្គមកាន់តែប្រសើរ។

**សេរីភាពនៃការបញ្ចេញមតិ៖** សេរីភាពក្នុងការបញ្ចេញមតិ រាប់បញ្ចូលទាំងសិទ្ធិក្នុងការស្វែងរកទទួល និងចែករំលែកព័ត៌មាន និងគំនិតគ្រប់ប្រភេទ។ សេរីភាពនេះ រួមបញ្ចូលទាំងព័ត៌មាន និងគំនិតនានានៅក្នុង

បញ្ហានយោបាយ និងសាសនា កិច្ចការសាធារណៈ សិទ្ធិមនុស្ស ក៏ដូចជាការសំដែងវប្បធម៌និងសិល្បៈ។ វិសាលភាពនេះ គ្របដណ្តប់យកការសំដែងមតិដែលអាចចាត់ទុកថា ជាការវាយប្រហារយ៉ាងខ្លាំង ដែលស្ថិតក្រោម ការកម្រិតព្រំដែន (ឧទា. សូមមើលផែនការសកម្មភាព Rabat ស្តីពីការហាមឃាត់ការឃោសនាឲ្យមានអំពើស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់ឲ្យមានការរើសអើង អរិយភាព ឬអំពើហិង្សា កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២)។ រាល់ទម្រង់ទាំងអស់នៃការសំដែងមតិ និងមធ្យោបាយនៃការផ្សព្វផ្សាយ ត្រូវទទួលបានការការពារ៖ ការបញ្ចេញមតិជាពាក្យសំដី ជាលាយលក្ខណ៍អក្សរ និងភាសាសញ្ញា និងការបញ្ចេញមតិមិនមែនពាក្យសំដីតាមរយៈរូបភាព និងឧបករណ៍នៃសិល្បៈ។ ការសំដែងមតិអាចធ្វើឡើងតាមរយៈសៀវភៅ កាសែត ខិត្តប័ណ្ណ ផ្ទាំងរូបភាព គំនូរជីវចល បដា សំលៀកបំពាក់ និងពាក្យបណ្តឹងស្របច្បាប់ផ្សេងៗ។ វារួមបញ្ចូលរាល់ទម្រង់នៃការសំដែងមតិជាសម្លេង-សោតទស្សន៍ ក៏ដូចជាអេឡិចត្រូនិក និងអ៊ីនធើណិត។

**សេរីភាពក្នុងការបង្កើតសមាគម៖** សមាគម សំដៅទៅលើក្រុមមនុស្ស ឬនីតិបុគ្គលណាមួយដែលរួមគ្នាធ្វើ សកម្មភាព សំដែង លើកកម្ពស់ ស្វែងរក ឬការពារផលប្រយោជន៍រួម។ ឧទាហរណ៍នៃសេរីភាពខាងសមាគម រួមមានការចូលជាសមាជិក និងការចូលរួមឬការជ្រើសរើសមិនចូលរួមក្នុងអង្គការសង្គមស៊ីវិល ក្លឹប សហគមន៍ អង្គការក្រៅរដ្ឋាភិបាល សមាគមសាសនា គណបក្សនយោបាយ សហជីព មូលនិធិ ឬសមាគមអនឡាញនានា។ "សមត្ថភាពស្វែងរក ទទួលបាន និងប្រើប្រាស់ធនធាន គឺមានសារៈសំខាន់ជាសារវ័ន្តចំពោះអត្ថិភាព និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់សមាគមណាមួយ ដោយមិនគិតថាសមាគមនោះតូច ឬធំនោះឡើយ។ សិទ្ធិសេរីភាពខាងសមាគម រាប់បញ្ចូលទាំងសិទ្ធិក្នុងការស្វែងរក ទទួល និងប្រើប្រាស់ធនធានធនធានមនុស្ស សម្ភារៈ និងហិរញ្ញវត្ថុពីប្រភពក្នុងប្រទេសក្រៅប្រទេស និងអន្តរជាតិ" (A/HRC/23/39, para. 8)។

**សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី៖** ការជួបប្រជុំដោយសន្តិវិធី គឺជាការប្រមូលគ្នាបណ្តោះអាសន្នដោយអហិង្សានៅតាមកន្លែងឯកជន និងសាធារណៈសម្រាប់គោលបំណងជាក់លាក់។ សកម្មភាពនេះរាប់បញ្ចូលទាំង ការធ្វើបាតុកម្ម កូដកម្ម ការដើរហែក្បួន ការប្រមូលផ្តុំ ឬការអង្គុយតវ៉ានៅមួយកន្លែង។ **សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ៖** ការអនុវត្តកិច្ចការសាធារណៈ គឺជាទស្សនទានទូលំទូលាយមួយដែលទាក់ទងនឹងការប្រើប្រាស់អំណាចនយោបាយជាពិសេសការប្រើប្រាស់អំណាចនីតិប្បញ្ញត្តិ ប្រតិបត្តិ និងរដ្ឋបាល។ វាគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃរដ្ឋបាលសាធារណៈ និងការតាក់តែង និងអនុវត្តគោលនយោបាយនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។ ការចូលរួមអាចធ្វើឡើងតាមរយៈអ្នកតំណាងដែលបានជ្រើសរើសដោយសេរី ឬដោយផ្ទាល់ ការអនុម័ត ឬការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ ការធ្វើសេចក្តីព្រាងច្បាប់ និងការបង្កើតគោលនយោបាយ ការសម្រេចចិត្តលើបញ្ហាសាធារណៈតាមរយៈការធ្វើប្រជាមតិ ការចូលរួមក្នុងសភាប្រជាជនដែលមានអំណាចក្នុងការសម្រេចចិត្តលើបញ្ហាមូលដ្ឋាន។ សិទ្ធិសេរីភាពខាងសមាគម ដែលរាប់ បញ្ចូលទាំងសិទ្ធិបង្កើត និងចូលរួមក្នុងអង្គការ និងសមាគមដែលពាក់ព័ន្ធនឹងកិច្ចការនយោបាយ និងសាធារណៈ គឺមានសារៈសំខាន់ជាសារវ័ន្តចំពោះសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ។

**ការមិនរើសអើង៖** សិទ្ធិទាំងអស់ខាងលើ ត្រូវបានធានាការពារដល់បុគ្គលគ្រប់រូបដោយគ្មានភាពខុសគ្នា ដូចជាជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនននយោបាយ និងទស្សនៈផ្សេងៗទៀត អត្តសញ្ញាណយេនឌ័រ ដើមកំណើតជាតិសាសន៍ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈដទៃទៀតឡើយ។ សិទ្ធិទាំងនេះ អនុវត្តទៅលើស្ត្រី កុមារ ប្រជាជនដើមភាគតិច ជនពិការ បុគ្គលដែលស្ថិតក្នុងក្រុមភាគតិច ឬក្រុមប្រឈមមុខនឹងភាពឯកោ ឬការផាត់ចេញ រួមទាំងជនរងគ្រោះដោយការរើសអើងដោយសារតែទំនោរផ្លូវភេទ របស់ពួកគេ និងអត្តសញ្ញាណយេនឌ័រ ជនគ្មានសញ្ជាតិ រួមទាំងបុគ្គលគ្មានរដ្ឋ ជនភៀសខ្លួន ឬជនទេសន្តរប្រវេសន៍ ក៏ដូចជាសមាគម រាប់បញ្ចូលទាំងក្រុមមិនបានចុះបញ្ជីផងដែរ។

ស្តង់ដារអន្តរជាតិទាំងនេះ អនុវត្តចំពោះគ្រប់អង្គទាំងអស់របស់រដ្ឋ៖ អង្គប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និងតុលាការ អាជ្ញាធរសាធារណៈ ឬរដ្ឋាភិបាលផ្សេងទៀតនៅគ្រប់កម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ។ រដ្ឋក៏ត្រូវតែការពារផងដែរដល់បុគ្គលផ្សេងៗឲ្យរួចផុតពីអំពើដែលបង្កឡើងដោយបុគ្គលឯកជន ឬនីតិបុគ្គល ដែលធ្វើឲ្យប៉ះពាល់ដល់ការទទួលបានសេរីភាពទាំងឡាយ។ រដ្ឋមានការទទួលខុសត្រូវចម្បងក្នុងការលើកកម្ពស់ និងការពារការអនុវត្តសិទ្ធិទាំងនេះ។

សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការបង្កើតសមាគម និងក្នុងការជួបប្រជុំដោយសន្តិវិធី ត្រូវមានកាតព្វកិច្ចនិងការទទួលខុស ត្រូវពិសេស ហើយដូច្នេះការអនុវត្តសេរីភាពទាំងនេះ អាចស្ថិតនៅក្រោមការកម្រិតព្រំដែនមួយចំនួន។ ការរិតត្បឹតណាមួយត្រូវតែមានចែងដោយច្បាប់ហើយត្រូវតែចាំបាច់បំផុតសម្រាប់គោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬសម្រាប់ការការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខភាពសាធារណៈ ឬសីលធម៌។ មូលដ្ឋានទាំងនេះ មិនត្រូវបានគេប្រើប្រាស់ជាហេតុផលមួយ ដើម្បីបិទមាត់ការតស៊ូមតិណាមួយដែលធ្វើឡើងតាមបែបប្រជាធិបតេយ្យពហុបក្ស លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើយ។

**គណៈកម្មាធិការសិទ្ធិមនុស្ស កំណត់ពន្យល់ទូទៅលេខ ៣៤ មាត្រា១៩៖ សេរីភាពខាងទស្សនៈ និងខាងការបញ្ចេញមតិ លេខ CCPR/C/GC/34; និងកំណត់ពន្យល់ទូទៅលេខ ២៥ មាត្រា២៥៖ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈលេខ CCPR/C/21/Rev.1/Add.7។ របាយការណ៍របស់ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងក្នុងការបង្កើតសមាគមលេខ A/HRC/20/27 និងលេខ A/HRC/23/39។**

"គ្មាននរណាម្នាក់ក្នុងចំណោមយើងទាំងអស់គ្នា រួមទាំងរដ្ឋាភិបាលផងដែរ មានគ្រប់អង្គហេតុទាំងអស់ គំនិតល្អបំផុត ឬដឹងគ្រប់ហេតុផលដែលនៅពីក្រោយ បញ្ហាទាំងឡាយដែលយើងកំពុងព្យាយាមដោះស្រាយឡើយ។ យើង អាចទទួលបានអត្ថប្រយោជន៍តែពីគតិបណ្ឌិតរួមគ្នាប៉ុណ្ណោះ។ ហើយដូច្នេះ វាមានសារៈសំខាន់ណាស់ដែលយើងត្រូវតែស្តាប់ពីគ្រប់បុគ្គល ជាពិសេសក្រុមដែលគេមិនបានគិតគូរដល់ មុននឹងធ្វើការសម្រេចចិត្ត។ ឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្ស ប្រមូលព័ត៌មានពីប្រភពផ្សេងៗជាច្រើន៖ ពីរដ្ឋាភិបាលខ្លួនឯង អង្គការសហប្រជាជាតិ និងសង្គមស៊ីវិល។ ការធ្វើបែបនេះជួយប្រាប់ឲ្យបានដឹងអំពីការសន្និដ្ឋានចុងក្រោយ និងអនុសាសន៍របស់យើង ដែលកំណត់ជាវិធានការជាក់ស្តែងសម្រាប់រដ្ឋាភិបាលដើម្បីចាត់ឡើង ធ្វើឲ្យច្បាប់ និងការអនុវត្តរបស់ខ្លួនឲ្យកាន់ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលពួកគេបានផ្តល់សច្ចាប័ន"។

សាស្ត្រាចារ្យ Sir Nigel Rodley ប្រធាន
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ខែតុលា ឆ្នាំ២០១៤

# ៤. បញ្ហាប្រឈមដែលតួអង្គសង្គមស៊ីវិលជួបប្រទះ

នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់សកល តួអង្គសង្គមស៊ីវិល អាចជួបប្រទះឧបសគ្គផ្សេងៗ ដែលមានគោលបំណងរារាំង កាត់បន្ថយ បញ្ឈប់ ឬផ្លាស់ប្តូរឥទ្ធិពលនៃសកម្មភាពស្របច្បាប់របស់ពួកគេ ដោយសារតែពួកគេរិះគន់ ឬប្រឆាំងនឹងគោលជំហរ គោលនយោបាយ ឬសកម្មភាពរបស់រដ្ឋាភិបាល។

ឧបសគ្គទាំងនេះ អាចរួមបញ្ចូលការរឹតត្បិតលើសេរីភាព និងឯករាជ្យភាព ឬការយាយី ការបំភិតបំភ័យ និងការសងសឹក (ឧទា. ការដាក់ទណ្ឌកម្ម ឬការសងសឹក) ប្រឆាំងនឹងតួអង្គសង្គមស៊ីវិល។

### វិធីដើម្បីបង្ការ កាត់បន្ថយ បញ្ឈប់ ឬផ្លាស់ប្តូរឥទ្ធិពលនៃការងាររបស់សង្គមស៊ីវិល




## ៤.១ វិធានការដែលផ្អែកលើច្បាប់ឬវិធាន ដែលជាឧបសគ្គដល់ការងារ របស់សង្គមស៊ីវិល

ច្បាប់ និងបទប្បញ្ញត្តិ អាចកម្រិតសេរីភាព និងឯករាជ្យភាពរបស់តួអង្គសង្គមស៊ីវិល ឧទាហរណ៍ ដោយ៖

- តម្រូវឲ្យចុះបញ្ជីដោយគ្មានអត្ថប្រយោជន៍វិជ្ជមាន (ឧទា. អត្ថប្រយោជន៍ផ្នែកពន្ធ)
- ការដាក់កម្រិតថាតើប្រភេទសកម្មភាពអ្វីខ្លះ អាចធ្វើបាន
- ទណ្ឌកម្មព្រហ្មទណ្ឌចំពោះសកម្មភាពដែលមិនបានចុះបញ្ជី

- ការរឹតត្បិតដែលត្រូវបានដាក់ទៅលើការចុះបញ្ជីសមាគមជាក់លាក់ រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬសមាគមដែលទទួលថវិកាពីបរទេស ឬក្រុមដែលធ្វើការងារលើសិទ្ធិមនុស្ស។
- ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ថាតើនរណាខ្លះ ឬអ្វីខ្លះ អាចធ្វើសកម្មភាពបាន ឬដាក់កម្រិតសកម្មភាពទាំងនោះ
- ការរឹតត្បិតប្រភពផ្តល់ហិរញ្ញវត្ថុ (ពោលគឺ ប្រភពពីបរទេស) និង
- ច្បាប់គ្រប់គ្រងសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី ខាងការបង្កើតសមាគម និងខាងការបញ្ចេញមតិដែលមានបទប្បញ្ញត្តិរើសអើង ឬមានផលប៉ះពាល់អវិជ្ជមានដោយអសមាមាត្រមកលើក្រុមខ្លះ។

បន្ថែមពីលើនេះ នីតិវិធីរដ្ឋបាលស្មុគ្រស្មាញ និងវិធានការឆន្ទានុសិទ្ធិ អាចរារាំង ឬពន្យារពេលតួអង្គសង្គមស៊ីវិល មិនឲ្យអនុវត្តសកម្មភាពរបស់ខ្លួនបាន។

នៅពេលសិទ្ធិសេរីភាពទទួលបានព័ត៌មានត្រូវបានកាត់បន្ថយ តួអង្គសង្គមស៊ីវិលមានលទ្ធភាពកាន់តែតិចតួចក្នុងការធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពនៅក្នុងសៃវៀនតាក់តែងគោលនយោបាយ។ បែបបទចូលរួមដែលមានលក្ខណៈចង្អៀត ឬតឹងរឹងដោយហួសហេតុ (ឧទា. "ឋានៈអ្នកសង្កេតការណ៍" ដែលផ្តល់ជូនតួអង្គសង្គមស៊ីវិល ឬការកម្រិតលើសិទ្ធិក្នុងការនិយាយ) នៅក្នុងដំណើរការធ្វើការសម្រេចចិត្ត ក៏ជារបាំងផងដែរ ចំពោះការចូលរួម។ ស្តង់ដារនៃសេរីភាពខាងសមាគម ត្រូវតែយកអនុវត្តនៅថ្នាក់អន្តរជាតិឲ្យបានច្រើនដូចគ្នានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។[3]

## ៤.២ វិធានការតាមទំនើងចិត្ត

នៅពេលសង្គមស៊ីវិល ធ្វើការរិះគន់ ឬប្រឆាំងនឹងគោលជំហរ គោលនយោបាយ និងសកម្មភាពរបស់រដ្ឋាភិបាល បទប្បញ្ញត្តិមិនច្បាស់លាស់នៅក្នុងច្បាប់ អាចត្រូវបានគេយកមកអនុវត្តតាមទំនើងចិត្ត ក្រោមលេសនៃនីត្យានុកូលភាព និងធម្មនុរូបភាព (ឧទា. ការប្រឆាំងការលាងសំអាតប្រាក់ ប្រឆាំងភេរវកម្ម សន្តិសុខជាតិ សីលធម៌សាធារណៈ ការបរិហារកេរ្តិ៍ ការការពារអធិបតេយ្យភាពជាតិ) ដែលស្មើទៅនឹង៖

- ការត្រួតពិនិត្យតាមទំនើងចិត្តទៅលើការគ្រប់គ្រង និងអភិបាលកិច្ចផ្ទៃក្នុង
- ការគំរាមកំហែងលុបចេញពីបញ្ជិកា ឬការលុបចេញពីបញ្ជិកាជាក់ស្តែង
- ការបង្ខំឲ្យបិទការិយាល័យ
- ការឆែកឆេរ និងការរឹបអូសទ្រព្យសម្បត្តិ

3 របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធីនិងការបង្កើតសមាគម ការធ្វើការប្រមូលផ្តុំដោយសន្តិវិធីនិងសមាគមក្នុងបរិបទនៃស្ថាប័នពហុភាគី, A/69/365.

- ការពិន័យជាប្រាក់ច្រើនហួសហេតុ
- ការផ្តន្ទាទោសដោយមិនត្រឹមត្រូវ
- ការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត
- ការហាមឃាត់លើការធ្វើដំណើរ
- ការដកហូតសញ្ញាតិ និង
- ការកម្រិតព្រំដែន ឬការលុបចោលតាមទំនើងចិត្តទៅលើការតវ៉ា ឬការប្រមូលផ្តុំ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ២៤/២១ ស្តីពីការបង្កើតនិងការរក្សាទុកនៅក្នុងច្បាប់ និងក្នុងការអនុវត្តជាក់ស្តែង នូវបរិយាកាសសុវត្ថិភាព និងអំណោយផលមួយសម្រាប់សង្គមស៊ីវិល កំណត់សម្គាល់ "នៅក្នុងករណីខ្លះ បទប្បញ្ញត្តិច្បាប់ និងរដ្ឋបាលក្នុងស្រុក... ត្រូវបានស្វែងរក ឬត្រូវបានប្រើប្រាស់ ខុសដើម្បីបង្កជាឧបសគ្គដល់ការងារ និងធ្វើឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់សង្គមស៊ីវិល ដែលផ្ទុយទៅនឹងច្បាប់អន្តរជាតិ"។

## ៤.៣ ការយាយី ការបំភិតបំភ័យ និងការសងសឹកក្រៅច្បាប់

បន្ថែមពីលើការកម្រិតដែលធ្វើឡើងតាមច្បាប់ និងតាមការយកច្បាប់មកអនុវត្តតាមទំនើងចិត្ត ដែលអាចរឹតត្បិតដល់លំហសម្រាប់សង្គមស៊ីវិល ការគំរាមកំហែង ឬការដាក់សម្ពាធខាងផ្លូវចិត្តតាមទម្រង់ផ្សេងៗ ឬការវាយប្រហារលើរូបរាងកាយដែលផ្តោតគោលដៅលើតួអង្គសង្គមស៊ីវិល ឬគ្រួសាររបស់ពួកគេ អាចជាការរារាំងពួកគេមិនឲ្យធ្វើការដោយសេរី។

ឧទាហរណ៍រួមមាន៖

- ការគំរាមកំហែងតាមសារទូរស័ព្ទ
- ការឃ្លាំមើល
- ការបំពានលើរូបរាងកាយ ឬផ្លូវភេទ
- ការបំផ្លាញទ្រព្យសម្បត្តិ
- ការដកហូតការងារ ឬការបាត់បង់ប្រាក់ចំណូល
- ការឃោសនាបង្ខូចលាបពណ៌តួអង្គសង្គមស៊ីវិលថាជា "សត្រូវរបស់រដ្ឋ" "ជនក្បត់" ឬថាធ្វើការដើម្បីផលប្រយោជន៍បរទេស
- ការបាត់ខ្លួន
- ទារុណកម្ម និង
- ការសម្លាប់។

"ជារឿយៗប្រជាពលរដ្ឋ និងក្រុមសង្គមស៊ីវិល តែងតែ ប្រថុយជីវិតរបស់ពួកគេ ដើម្បីធ្វើប្រសើរដល់ជីវិតរបស់អ្នកដទៃ។ ពួកគេ ហ៊ាននិយាយចេញ ទោះបីជានៅពេលដឹងថា ពួកគេអាចត្រូវបានគេបំបិទមាត់រហូតក៏ដោយ។ ពួកគេលើកឡើងអំពីបញ្ហាដែលអ្នកដទៃមិនយកចិត្តទុកដាក់ ឬអាចមិនបានដឹងថាមានបញ្ហាទាំងនោះ។ ពួកគេការពារសិទ្ធិរបស់យើង។ ពួកគេសមនឹងទទួលបានសិទ្ធិរបស់ពួកគេ"។

សុន្ទរកថារបស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ<br>
នៅឯកិច្ចប្រជុំជាន់ខ្ពស់ស្តីពីការគាំទ្រដល់សង្គមស៊ីវិល<br>
ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

"អំពើយាយី ការបំភិតបំភ័យ និងការសងសឹក ដាក់សម្ពាធដល់សកម្មជនសិទ្ធិមនុស្ស ឬសាក្សី មិនឲ្យសំដែងកង្វល់ផ្សេងៗ និងមិនឲ្យធ្វើការជាមួយអង្គការសហប្រជាជាតិ ឬតួអង្គអន្តរជាតិដទៃទៀត។ ក្នុងពេលជាមួយគ្នានេះ អំពើទាំងនេះ គឺជាការបង្កឲ្យមានការភ័យខ្លាចនៅក្នុងចំណោមសាធារណជនទូទៅនិងបង្កើតបរិយាកាសជិះជាន់មួយ ដែលបំបិទសេរីភាពខាងការបញ្ចេញមតិ ខាងការបង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី ដែលមានសារៈសំខាន់ជាសារវ័ន្តសម្រាប់សង្គមប្រជាធិបតេយ្យមួយ"។

លោក Laura Dupuy Lasserre ឯកអគ្គរដ្ឋទូត<br>
ដែលជាតំណាងអចិន្ត្រៃយ៍របស់ប្រទេសអ៊ុយរូហ្គាយប្រចាំការិយាល័យអង្គការសហប្រជាជាតិ<br>
នៅទីក្រុងហ្សឺណែវ និងប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស (២០១១-២០១២)

## អ្នកការពារសិទ្ធិមនុស្សជាស្ត្រី

អ្នកការពារសិទ្ធិមនុស្សជាស្ត្រី (WHRDs) ស្ថិតនៅក្រោមហានិភ័យមួយចំនួនដូចគ្នានឹងសមភាគីជាបុរសរបស់ខ្លួនដែរ ប៉ុន្តែ ជាស្ត្រី ពួកគេក៏ជាគោលដៅសម្រាប់ ឬប្រឈមនឹងការគំរាមកំហែងផ្អែកលើយេនឌ័រ និងអំពើហិង្សាផ្អែកលើយេនឌ័រ។ ជារឿយៗ ការងាររបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ត្រូវបានមើលឃើញថាជាការប្រឈមនឹងទស្សនៈប្រពៃណីរបស់គ្រួសារ និងតួនាទីយេនឌ័រនៅក្នុងសង្គម ដែលអាចនាំទៅកាន់ អរិយភាពពីប្រជាពលរដ្ឋទូទៅ និងអាជ្ញាធរ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ប្រឈមមុខនឹងការប្រមាថមាក់ងាយ និងការផាត់ចេញពីសង្គមដោយមេដឹកនាំសហគមន៍ ក្រុមជឿលើជំនឿ គ្រួសារ និងសហគមន៍ដែលចាត់ពួកគេថា កំពុងតែគំរាម កំហែងដល់សាសនា កិត្តិយស ឬវប្បធម៌ តាមរយៈការងាររបស់ពួកគេ។

បន្ថែមពីលើនេះ ការងារតែម្តង ឬអ្វីដែលពួកគេកំពុងខិតខំសម្រេចឲ្យបាន (ឧទាហរណ៍ ការធ្វើសម្រេចបានសិទ្ធិស្ត្រី ឬសិទ្ធិទាក់ទងនឹងយេនឌ័រណាមួយ) ក៏ធ្វើឲ្យពួកគេជាគោលដៅសម្រាប់ការវាយប្រហារផងដែរ។ គ្រួសាររបស់ពួកគេ ក៏ក្លាយជាគោលដៅនៃការគំរាមកំហែង និងអំពើហិង្សាផងដែរ

ដែលមានគោលបំណងធ្វើឲ្យអ្នកការពារសិទ្ធិមនុស្សជាស្ត្រីមាននៅឯកោ និងបំបាក់ទឹកចិត្តពួកគេមិនឲ្យបន្តការងាររបស់ខ្លួន។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ប្រឈមមុខនឹងទម្រង់ផ្សេងៗនៃអំពើហិង្សា និងអំពើរំលោភដទៃទៀត បុរេនិច្ឆ័យ ការផាត់ចេញពីសង្គម និងការលែងរាប់រកច្រើនជាងសមភាគីបុរសរបស់ពួកគេ។ បញ្ហាប្រឈមជាក់លាក់ទាំងនេះ ត្រូវតែទទួល ស្គាល់ ដើម្បីពង្រឹងយន្តការការពារ និងការឆ្លើយតបដទៃទៀតទាំងនៅថ្នាក់ជាតិ និងអន្តរជាតិចំពោះកង្វល់របស់ពួកគេ។ ការស៊ើបអង្កេតជាបន្ទាន់ និងដោយហ្មត់ចត់ទៅលើការបំភិតបំភ័យ ការគំរាមកំហែង អំពើហឹង្សា និងការរំលោភបំពានផ្សេងទៀតប្រឆាំងអ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រី ទោះជាធ្វើឡើងដោយរដ្ឋក្តី ឬតួអង្គ មិនមែនរដ្ឋក្តី គួរត្រូវបានធ្វើឡើង។

នៅក្នុងឆ្នាំ២០១៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចលើកដំបូងដែលមិនធ្លាប់មានពីមុនមករបស់ខ្លួន គឺសេចក្តីសម្រេចលេខ៦៨/១៨១ស្តីពីអ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលបានសំដែងការព្រួយបារម្ភពិសេសអំពីការរើសអើងលក្ខណៈជាប្រព័ន្ធនិងជារចនាសម្ព័ន្ធ និងអំពើហិង្សាដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីគ្រប់វ័យបានជួបប្រទះ ហើយបានអំពាវនាវដល់រដ្ឋឲ្យចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាការការពារដល់ពួកគេ ព្រមទាំងដាក់បញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីបង្កើតឲ្យមានបរិយាកាសប្រកបដោយសុវត្ថិភាព និងមានអំណោផលមួយសម្រាប់ការពារសិទ្ធិមនុស្ស។

នៅប្រទេស Cote d'Ivoire ច្បាប់ស្តីពីការលើកកម្ពស់ និងការការពារអ្នកការពារសិទ្ធិមនុស្សឆ្នាំ២០១៤ មានចែងអំពីសិទ្ធិជាច្រើនដែលត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស រួមទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សិទ្ធិក្នុងការប្រើប្រាស់ធនធាន សិទ្ធិក្នុងការដាក់ជូនព័ត៌មានទៅកាន់ស្ថាប័នអន្តរជាតិ និងសិទ្ធិទទួលបានការការពាររួចផុតពី ការសងសឹក។ ច្បាប់នេះ ដាក់បញ្ចូលកាតព្វកិច្ចក្នុងការការពារអ្នកការពារសិទ្ធិមនុស្ស គ្រួសាររបស់ពួកគេ និងផ្ទះរបស់ពួកគេ ពីការវាយប្រហារ និងកាតព្វកិច្ចស៊ើបអង្កេតនិងដាក់ទណ្ឌកម្មចំពោះការវាយប្រហារនានា ដែលកើតមានឡើង។ ច្បាប់នេះ ទទួលស្គាល់ការគំរាមកំហែងពិសេសដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីជួបប្រទះ និងតម្រូវការការពាររបស់ពួកគេ។ ច្បាប់របស់ប្រទេស Cote d'Ivoire ត្រូវបានស្វាគមន៍ដោយអង្គការសង្គមស៊ីវិល រួមទាំងសម្ព័ន្ធភាពនៃអ្នកការពារសិទ្ធិមនុស្សនៃប្រទេស Cote d'Ivoire និងបណ្តាញអ្នកការពារសិទ្ធិមនុស្សប្រទេសអាហ្វ្រិកខាងលិច។

## ការបំភិតបំភ័យ និងការសងសឹកប្រឆាំងបុគ្គល និងក្រុមនានាដែលសហការជាមួយអង្គការសហប្រជាជាតិ

"សង្គមស៊ីវិល គឺជាផ្នែកដ៏សំខាន់បំផុតក្នុងការការជំរុញការងាររបស់អង្គការសហប្រជាជាតិតាមរយៈរបៀបវារៈរបស់យើង មិនត្រឹមតែដើម្បីសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថៃទាំងដើម្បីសន្តិភាព និងសន្តិសុខក៏ដូចជាការអភិវឌ្ឍផងដែរ។ សង្គមស៊ីវិល មិនដែលមានសារៈសំខាន់ និងត្រូវការគ្រប់។ ការសងសឹក និងការបំភិតបំភ័យប្រឆាំងជនទាំងឡាយណាដែលសហការជាមួយអង្គការសហប្រជាជាតិ គឺមិនអាចទទួលយកបានឡើយមិនត្រឹមតែដោយសារតែពួកគេជួយយើងធ្វើការដែលផ្តល់អាណត្តិដោយធម្មនុញ្ញ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែពួកគេ ក៏មានគោលបំណងមិនលើកទឹកចិត្តដល់អ្នកដទៃមិនឲ្យធ្វើការជាមួយយើងផងដែរ។ យើងត្រូវតែចាត់វិធានការនៅគ្រប់កម្រិតថ្នាក់ដើម្បីពង្រឹងសម្លេងប្រជាធិយតេយ្យ។"

សុន្ទរកថារបស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ
នៅឯកិច្ចប្រជុំជាន់ខ្ពស់ស្តីពីការគាំទ្រដល់សង្គមស៊ីវិល
ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

"អង្គការសហប្រជាជាតិ មិនអាចបំពេញការងារដ៏មានតម្លៃរបស់ខ្លួនដើម្បីសិទ្ធិមនុស្សបានទេ ប្រសិនបើគ្មានអ្នកសហការជាមួយយើង។ នៅពេលពួកគេ ត្រូវបានបំភិតបំភ័យ និងជាគោលដៅនៃការសងសឹក ពួកគេគឺជាជនរងគ្រោះ ប៉ុន្តែយើងទាំងអស់គ្នាក៏ទទួលរងនូវបញ្ហាអសន្តិសុខដែរ។ នៅពេលកិច្ចសហការរបស់ពួកគេត្រូវបានរារាំង ការងាររបស់យើងនៅក្នុងវិស័យសិទ្ធិមនុស្សក៏ត្រូវប៉ះពាល់ដែរ។"

សុន្ទរកថារបស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ
នៅឯកិច្ចពិភាក្សាគណៈវាគ្មិនជាន់ខ្ពស់ស្តីពីការសងសឹក
ក្រុងញូយ៉ក ឆ្នាំ២០១១

អ្វីដែលគួរឲ្យរន្ធត់បំផុតនោះ គឺអំពើនៃការបំភិតបំភ័យ និងការសងសឹកប្រឆាំងនឹងបុគ្គល ឬក្រុមនានាដែលសហការជាមួយអង្គការសហប្រជាជាតិក្នុងវិស័យសិទ្ធិមនុស្ស។ ទោះបីជាមានការទទួលស្គាល់ជាសកលពីតម្រូវការ និងសិទ្ធិរបស់បុគ្គលនិងក្រុមផ្សេងៗក្នុងការចូលរួមក្នុងការងាររបស់ប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិក៏ដោយ ក៏អំពើទាំងនេះត្រូវបានរាយការណ៍ថា នៅតែបន្តកើតមានឡើង។

ដោយសារតែការចូលរួមរបស់ពួកគេជាមួយយន្តការ ឬមន្ត្រីរបស់អង្គការសហប្រជាជាតិ (ឧទា. ការចេញសេចក្តីថ្លែងការ ការដាក់ជូនរបាយការណ៍ ការចូលរួមកិច្ចប្រជុំ។ល។) តួអង្គសង្គមស៊ីវិលនីមួយៗ អាចប្រឈមមុខនឹងការបំភិតបំភ័យ ឬការសងសឹក ដូចជា ត្រូវបានគេគំរាមកំហែង ឬយាយីដោយមន្ត្រី

រដ្ឋាភិបាល រួមទាំងតាមរយៈសេចក្តីថ្លែងការណ៍សាធារណៈដោយអាជ្ញាធរជាន់ខ្ពស់ អាចជាការរារាំងមិនឲ្យធ្វើដំណើរ ដើម្បីចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ ហើយតួអង្គសង្គមស៊ីវិល អាចយល់ឃើញថា សកម្មភាពរបស់ពួកគេ ត្រូវបានគេតាមដាន ឬរឹតត្បិត។ ការឃោសនាលាបពណ៌តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ការបោះពុម្ពផ្សព្វផ្សាយ ឬទូរទស្សន៍ តែងកើតមានជាទូទៅ។ ការគំរាមកំហែង អាចត្រូវបានធ្វើឡើងតាមរយៈការហៅទូរស័ព្ទ សារតាមទូរស័ព្ទ ឬទំនាក់ទំនងដោយផ្ទាល់។ តួអង្គសង្គមស៊ីវិល អាចត្រូវបានគេចាប់ខ្លួន វាយដំ ធ្វើទារុណកម្ម ឬសម្លាប់ផងដែរ។

ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានអនុម័តសេចក្តីសម្រេចជាច្រើនស្តីពីបញ្ហានេះ រួមទាំងសេចក្តីសម្រេចលេខ២៤/២៤ និងសេចក្តីសម្រេចលេខ១២/២។ អគ្គលេខាធិការ រាយការណ៍ប្រចាំឆ្នាំអំពីករណីដែលគេអះអាងថាមានការសងសឹកដោយសារតែការសហការជាមួយអង្គការសហប្រជាជាតិក្នុងវិស័យសិទ្ធិមនុស្ស។ ទាំងអគ្គលេខាធិការ ទាំងឧត្តមស្នងការសិទ្ធិមនុស្ស បានបញ្ជាក់ម្តងហើយម្តងទៀតថា ការសងសឹកបែបនេះ គឺមិនអាចទទួលយកបានទេ ហើយថា ការឆ្លើយតបតាមលក្ខណៈរួបរួមគ្នា និងសម្របសម្រួលគ្នាកាន់តែច្រើនពីអង្គការ សហប្រជាជាតិទៅលើអំពើបែបនេះ គឺជាការចាំបាច់។ យន្តការសិទ្ធិមនុស្សផ្សេងទៀត ក៏ត្រូវប្រកាន់យកគោលជំហរខ្លាំងក្លានិងជាសាធារណៈមួយប្រឆាំងនឹងការសងសឹកផងដែរ។

## បទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សស្តីពីការសងសឹក

### ពិធីសារបន្ថែមលើកតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ -មាត្រា ១៣

រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីធានាថា បុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន មិនស្ថិតនៅក្រោមទម្រង់ណាមួយនៃការប្រព្រឹត្តិមិនគប្បី ឬការបំភិតបំភ័យ ដោយសារតែការប្រាស្រ័យទាក់ទងជាមួយគណៈកម្មាធិការស្របតាមពិធីសារបច្ចុប្បន្នឡើយ។

### ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារស្តីពីនីតិវិធីប្រាស្រ័យទាក់ទង-មាត្រា៤

រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីធានាថា បុគ្គលដែលនៅក្រោមយុត្តាធិការរបស់ខ្លួន មិនទទួលរងការរំលោភសិទ្ធិមនុស្ស ការប្រព្រឹត្តិមិនគប្បី ឬការបំភិតបំភ័យណាមួយ ដោយសារតែការទាក់ទង ឬការសហការជាមួយគណៈកម្មាធិការស្របតាមពិធីសារបច្ចុប្បន្នឡើយ។

### ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី-មាត្រា ១១

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីធានាថា បុគ្គលដែលនៅក្រោមយុត្តាធិការរបស់ខ្លួនមិនទទួលរងការប្រព្រឹត្តិមិនគប្បី ឬការបំភិតបំភ័យ ដោយសារតែការទាក់ទងជាមួយគណៈកម្មាធិការស្របតាមពិធីសារបច្ចុប្បន្នឡើយ។

> នៅក្នុងប្រទេសអូទ្រីស វាក្យខណ្ឌទី១៨នៃច្បាប់ស្តីពីគណៈទទួលពាក្យបណ្តឹង (Ombudsman Board Act) ចែងថា៖ "គ្មាននរណាម្នាក់ត្រូវបានដាក់ទោស ឬធ្វើបាត់បង់ផលប្រយោជន៍ដោយសារតែផ្តល់ព័ត៌មានដល់អនុគណៈកម្មការស្តីពីការទប់ស្កាត់ទារុណកម្ម គណៈទទួលពាក្យបណ្តឹង ឬគណៈកម្មការនានាដែលខ្លួនបានបង្កើតឡើយ ។
>
> "នៅក្នុងប្រទេសម៉ុងតេណេហ្គ្រូ (Montenegro) មាត្រា៥៦នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ចែងថា"ជនគ្រប់រូបមានសិទ្ធិប្រើប្រាស់ស្ថាប័នបអន្តរជាតិ ដើម្បីការពារសិទ្ធិ និងសេរីភាពដែលធានាដោយរដ្ឋធម្មនុញ្ញ។"

ការរឹតត្បិតដោយច្បាប់ និងរដ្ឋបាល រួមជាមួយការយាយី ការបំភិតបំភ័យ និងការសងសឹក កាត់បន្ថយ តួនាទីនៃភាពជាដៃគូក្នុងន័យស្ថាបនា និងបំពេញឲ្យគ្នាទៅវិញទៅមក ដែលសង្គមស៊ីវិលគួរបំពេញជាមួយ រដ្ឋាភិបាល។ ការរឹតត្បិតទាំងនេះ មានបំណងរារាំង កាត់បន្ថយ ធ្វើឲ្យខូចកិត្តិយស បង្អាក់ ឬបន្ថយឥទ្ធិពលការងារសង្គមស៊ីវិល។ ការខកខានក្នុងការលើកកម្ពស់ និងការពារលំហនេះ និងក្នុងការធានាឲ្យមានបរិយាកាសសុវត្ថិភាពនិងអំណោយផល គឺជាការរំលោភកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

រដ្ឋ ត្រូវមានការទទួលខុសត្រូវចម្បងក្នុងការការពារតួអង្គសង្គមស៊ីវិល ប៉ុន្តែនៅពេលលំហសង្គមស៊ីវិល ឬតួអង្គសង្គមស៊ីវិលខ្លួនឯង ប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារតែការងារដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់ពួកគេ សហគមន៍អន្តរជាតិ ក៏ត្រូវមានផលប្រយោជន៍ និងការទទួលខុសត្រូវរួមគ្នាដើម្បីគាំទ្រនិងការពារពួកគេ។



# ៥. តើខ្ញុំអាចធ្វើអ្វីបានខ្លះ? សូមទាក់ទងមកមើលអង្គការសហប្រជាជាតិ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ផ្ដល់វេទិកាអន្តរជាតិមួយដែលតួអង្គសង្គមស៊ីវិលអាចស្វែងរកការគាំទ្រ និងការណែនាំ ។ វេទិកានេះ រាប់បញ្ចូលទាំងការិយាល័យនៃឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងក្រុមប្រឹក្សាសិទ្ធិមនុស្ស ព្រមទាំងយន្ដការរបស់ខ្លួន (អាណត្តិនីតិវិធីពិសេស យន្ដការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។ល។)។

"ស្ដង់ដារសិទ្ធិមនុស្សអន្តរជាតិ ផ្ដល់ក្របខ័ណ្ឌការងារជាសកលមួយដែលផ្ដល់លទ្ធភាពឲ្យអង្គការពលរដ្ឋតស៊ូមតិ ដើម្បីធ្វើសម្រេចឲ្យបានបទដ្ឋានដែលមាន ការឯកភាពគ្នាជាអន្តរជាតិ។ ស្ដង់ដារទាំងនេះ មិនត្រឹមតែផ្ដល់ភាពស្របច្បាប់ដល់សកម្មភាពរបស់អង្គការពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់ជាវេទិកាដ៏មានសារៈប្រយោជន៍មួយផងដែរ ដើម្បីឃ្លាំមើល និងរាយការណ៍ដោយឯករាជ្យ ស្ដីពីកាព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិល។ យន្ដការសិទ្ធិមនុស្សអន្តរជាតិ គឺជាវេទិកាចាំបាច់មួយដែលតស៊ូមតិឲ្យមានបរិយាកាសកាន់តែអំណោយផលសម្រាប់សង្គមស៊ីវិល។ នៅក្នុងបរិបទមានការរឹតត្បឹត ស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ផ្ដល់នូវចំណុចចូលដ៏សំខាន់មួយសម្រាប់ក្រុមសង្គមស៊ីវិលជាតិក្នុងការផ្សព្វផ្សាយការយល់ដឹង និងសន្ទនាអំពីបញ្ហារសេីបនានា"។

លោកបណ្ឌិត Danny Sriskandarajah អគ្គលេខាធិការ CIVICUS: សម្ព័ន្ធភាពពិភពលោកដើម្បីការចូលរួមពលរដ្ឋ
ខែតុលា ឆ្នាំ២០១៤

មានមធ្យោបាយពីរ ដែលយន្ដការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អាចការពារលំហសង្គមស៊ីវិល បាន ។[4]

ការចងក្រងឯកសារអំពីឧបសគ្គ ការគំរាមកំហែងទៅលើលំហសង្គមស៊ីវិល និងការប្រតិបត្តិល្អៗ។ ការចងក្រងឯកសារអំពីស្ថានភាពសិទ្ធិមនុស្ស បង្កើតជាមូលដ្ឋានសម្រាប់អន្តរាគមន៍ដោយយន្ដការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ព័ត៌មានដែលបានចងក្រងជាឯកសារ និងផ្ទៀងផ្ទាត់ត្រឹមត្រូវដោយតួអង្គសង្គមស៊ីវិល បង្កើតបានជាករណីដ៏រឹងមាំសម្រាប់សកម្មភាព មានលក្ខណៈអាចជឿទុកចិត្តបាន និងមានភាពទាក់ទាញកាន់តែខ្លាំង ពិបាកបដិសេធ និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស។ តួអង្គសង្គមស៊ីវិល ត្រូវបានស្នើសុំឲ្យចែករំលែកឯកសារ (ឧទា. ព័ត៌មាន

4 អ្នកអានដែលមិនទាន់ដឹងអំពីលក្ខណៈចម្បងនៃយន្ដការទាំងនេះ សូមមើលមើលសៀវភៅសម្រាប់សង្គមស៊ីវិល របស់OHCHR ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការ សហប្រជាជាតិ។ ការណែនាំ និងយោបល់បន្ថែម មាននៅក្នុងមគ្គុទ្ទេសក៍អនុវត្តជាក់ស្ដែងសម្រាប់សង្គមស៊ីវិល រួមទាំងរបៀបតាមដានបន្ដអនុសាសន៍សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

ត្រឹមត្រូវ ព័ត៌មានអំពីអង្គហេតុ ការវិភាគដោយប្រុងប្រយ័ត្ន និងអនុសាសន៍ជាក់ស្តែង) អំពីឧបសគ្គការគំរាមកំហែងទៅលើតួអង្គសង្គមស៊ីវិល និងលំហការងាររបស់ពួកគេ ក៏ដូចជា ការជួយផ្តល់ការអនុវត្តល្អៗដល់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

ការប្រើប្រាស់លំហដែលមាន។ តួអង្គសង្គមស៊ីវិល ត្រូវបានស្នើសុំឲ្យប្រើឱកាសដើម្បីចូលរួមក្នុងសន្និសីទ និងកិច្ចប្រជុំអន្តរជាតិ ឬទស្សនកិច្ចរបស់អ្នកជំនាញ។ ឱកាស អាចមានតាមរយៈការដាក់ជូនរបាយការណ៍ ការរៀបចំកិច្ចប្រជុំផ្តល់ព័ត៌មាន និងការចងជាបណ្តាញក្នុងចំណោមអ្នកចូលរួម ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីបញ្ហាលំហសង្គមស៊ីវិល ក៏ដូចជា ចែករំលែកអនុសាសន៍ និងយុទ្ធសាស្ត្រប្រកបដោយជោគជ័យ។

ការធ្វើការជាមួយយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទៅលើបញ្ហាលំហសង្គមស៊ីវិល ផ្តល់ដល់តួអង្គសង្គមស៊ីវិល នូវលទ្ធភាពប្រើប្រាស់ទិន្នផល (ឧទា. ការរកឃើញ និងអនុសាសន៍របស់អន្តរជាតិចំពោះរដ្ឋាភិបាលនានា ស្តីពីវិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀត) នៅក្នុងការងាររបស់ពួកគេ ដើម្បីការពារលំហសង្គមស៊ីវិល និងផ្តល់សិទ្ធិអំណាចដល់តួអង្គសង្គមស៊ីវិលនៅក្នុងប្រទេស។




ឧទាហរណ៍អំពីលទ្ធផលនៃអាណត្តិ និងយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖

- សេចក្តីសន្និដ្ឋានចុងក្រោយរបស់ស្ថាប័នសន្ធិសញ្ញា ក៏ដូចជាទស្សនៈ និងអនុសាសន៍ស្តីពីករណីនីមួយៗ
- ការវាយតម្លៃ អនុសាសន៍ និងសេចក្តីសន្និដ្ឋានដែលមាននៅក្នុងរបាយការណ៍ស្តីពីទស្សនកិច្ចក្នុងប្រទេស របាយការណ៍តាមប្រធានបទ និងអនុសាសន៍ស្តីពីករណីនីមួយៗដោយនីតិវិធីពិសេស(អ្នកឯករាជ្យ) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។
- អនុសាសន៍ពីយន្តការត្រួតពិនិត្យរបាយការណ៍ជាសកលតាមពេលកំណត់
- ដំណោះស្រាយ និងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមហាសន្និបាតអង្គការសហប្រជាជាតិ

- របាយការណ៍របស់គណៈកម្មការស៊ើបអង្កេត បេសកកម្មស្វែងរកការពិត និងយន្តការពិសេសស៊ើបអង្កេតសិទ្ធិមនុស្សចំពោះកិច្ចដទៃទៀតដែលបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស
- សេចក្តីថ្លែងការណ៍ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ
- សេចក្តីថ្លែងការណ៍ របាយការណ៍ និងការសិក្សារបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ឧទា. របាយការណ៍ស្តីពីសកម្មភាពរបស់ការិយាល័យនៅតាមប្រទេសផ្សេងៗ របាយការណ៍ និងការសិក្សាស្តីពីស្ថានភាពប្រចាំប្រទេស និងតាមប្រធានបទដែលផ្តល់អាណត្តិការងារដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ឬមហាសន្និបាតអង្គការសហប្រជាជាតិ)
- របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការស្តីពីករណីបំភិតបំភ័យ ឬសងសឹកប្រឆាំងនឹងបុគ្គល ឬក្រុមដែលសហការជាមួយអង្គការសហប្រជាជាតិក្នុងវិស័យសិទ្ធិមនុស្ស និង
- សេចក្តីអំពាវនាវទៅកាន់ប្រទេសទាំងឡាយដោយអគ្គលេខាធិការ ឧត្តមស្នងការសិទ្ធិមនុស្ស ឬដោយអ្នកជំនាញសិទ្ធិមនុស្សនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ។

ការរកឃើញ និងអនុសាសន៍ទាំងនេះ ក៏អាចជាឧបករណ៍នៃការតស៊ូមតិ និងការណែនាំដ៏មានឥទ្ធិពលដើម្បីគាំទ្រ និងបង្កើតសកម្មភាពក្នុងស្រុក ក៏ដូចជាការការពារដែរ។ ឧទាហរណ៍ តួអង្គសង្គមស៊ីវិល អាច៖

- ធ្វើការជាមួយរដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដើម្បីអនុវត្តអនុសាសន៍ពីប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។
- ផ្សព្វផ្សាយការយល់ដឹងដល់សហគមន៍មូលដ្ឋានអំពីការវិភាគ និងការរំពឹងទុកជាអន្តរជាតិទៅលើការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រទេស
- ឃ្លាំមើល និងវាយតម្លៃការឆ្លើយតប និងវិធានការដែលអាជ្ញាធរនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានបានចាត់ធ្វើឡើង
- ពង្រឹងសម្ភារៈតស៊ូមតិដែលមានស្រាប់តាមរយៈភាសារដោយច្បាស់លាស់ និងដោយគ្មានលំអៀងយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព និងដំណោះស្រាយការអនុវត្តល្អៗ។
- ប្រមូលផ្តុំទស្សនៈនៅក្នុង និងនៅទូទាំងអង្គការសង្គមស៊ីវិល ក៏ដូចជាសាធារណជន
- កសាងភាពជាដៃគូ
- ធ្វើឲ្យប្រសើរឡើងដល់គុណភាពនៃកិច្ចសន្ទនាជាមួយមន្ត្រីសាធារណៈ
- ចូលរួមចំណែកដល់ការតាក់តែងគោលនយោបាយ
- រៀបចំវិធានការច្បាប់/បណ្តឹងវិវាទ
- រួមចំណែកក្នុងការអនុវត្តបន្តនីតិវិធីយន្តការសិទ្ធិមនុស្ស
- វាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសដល់បុគ្គលផ្សេងៗដែលមានបំណងដាក់ពាក្យបណ្តឹងទៅយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

ការរកឃើញរបស់អង្គការសហប្រជាជាតិទាក់ទងនឹងប្រទេសដទៃទៀត ក៏ជាប្រភពព័ត៌មានដ៏សម្បូណ៌បែបអំពីយុទ្ធសាស្ត្រនានាដែលទាក់ទងនឹងបទពិសោធន៍ស្រដៀងគ្នា នៅទីកន្លែងផ្សេងៗទៀតដែរ។

## របៀបយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិធ្វើការ

ជាទូទៅ យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុវត្តតាមដំណើរការស្រដៀងគ្នាមួយ ក្នុងការព្យាយាមដោះស្រាយបញ្ហាសិទ្ធិមនុស្ស។ ព័ត៌មាន ត្រូវបានប្រមូល ឬទទួលពីប្រភពផ្សេងៗជាច្រើន រួមទាំងតួអង្គសង្គមស៊ីវិលផងដែរ។ ព័ត៌មាននេះ ត្រូវបានវិភាគ ផ្ទៀងផ្ទាត់រកភាពស៊ីសង្វាក់ ភាពអាចជឿទុកចិត្តបាន និងភាពត្រឹមត្រូវ។ យន្តការនេះ ចាប់ផ្តើមកិច្ចសន្ទនាជាលាយលក្ខណ៍អក្សរ ឬដោយជួបផ្ទាល់ជាមួយរដ្ឋ ដើម្បីបំភ្លឺទៅលើ ខ្លឹមសារនៃព័ត៌មាននោះ។ យន្តការនេះ អាចផ្តល់អនុសាសន៍ដល់រដ្ឋអំពីរបៀបដោះស្រាយបញ្ហា និងផ្តល់ជំនួយដើម្បីជួយរដ្ឋ អនុវត្តអនុសាសន៍ទាំងនោះ។ បន្ទាប់មក ព័ត៌មានបន្ថែមទៀត ត្រូវបានប្រមូលដើម្បីវាយតម្លៃ ការជឿនលឿនទៅមុខទៅលើអនុសាសន៍ទាំងនោះ។



នៅក្នុងខែមេសា ឆ្នាំ២០១១ សមាជិកគណៈកម្មាធិការនៃអ្នកតំណាងជនពិការអេស្ប៉ាញ (CERMI) បានចូលរួមក្នុងសម័យប្រជុំលើកទី៥ របស់គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ (CRPD) ហើយបានរួមចំណែកដល់ការរៀបចំបញ្ជីបញ្ហា។ CERMI បានដាក់បញ្ជូនរបាយការណ៍ជូនដល់គណៈកម្មាធិការ ផ្តល់ព័ត៌មានសង្ខេបដល់ គណៈកម្មាធិការ ហើយបន្ទាប់មក បានធ្វើការតាមដានអនុសាសន៍ដែលបានផ្តល់ជូនប្រទេសអេស្ប៉ាញ។ ជាពិសេស CERMI បានបើកយុទ្ធនាការយ៉ាងទូលំទូលាយមួយ ដើម្បីឲ្យមានប្រគល់មកវិញនូវសិទ្ធិក្នុងការបោះ ឆ្នោតសម្រាប់ជនដែលត្រូវបានគេដកហូតសិទ្ធិបោះឆ្នោត ដោយសារតែពិការភាពរបស់ពួកគេ ដែលជាស្ថានភាព មួយធ្វើឲ្យប៉ះពាល់ដល់មនុស្សប្រមាណ ៨០.០០០នាក់ នៅពេលនោះ។ គណៈកម្មការ បានផ្តល់អនុសាសន៍ថា "រាល់ច្បាប់ពាក់ព័ន្ធទាំងអស់ត្រូវធ្វើការពិនិត្យឡើងវិញ ដើម្បីធានាថា ជនពិការទាំងអស់ ដោយមិនគិតពី ភាពពិការរបស់ពួកគេ ឋានៈផ្លូវច្បាប់ ឬទីកន្លែងរស់នៅឡើយ ត្រូវមានសិទ្ធិបោះឆ្នោត" (CRPD/C/ESP/CO/1 វាក្យខណ្ឌទី ៤៨)។ CERMI បានដាក់ឲ្យអនុវត្តនូវគំនិតផ្តួចផ្តើមជាច្រើន ដើម្បីគាំទ្រដល់ការធ្វើវិសោធនកម្មច្បាប់ រួមទាំងគោលការណែនាំមួយ មានចំណងជើងថា "អ្នកមានសិទ្ធិបោះឆ្នោត គ្មាននរណាអាចដកហូតយកសិទ្ធិនេះបានឡើយ" ដែលពិពណ៌នាលម្អិតអំពីជំហានជាក់ស្តែង ដើម្បីទាមទារ និងអនុវត្តសិទ្ធិបោះឆ្នោត។ ជាលទ្ធផលនៃការតស៊ូមតិរបស់ CERMI ព្រះរាជអាជ្ញានៃតុលាការកំពូល បានជំរុញឲ្យព្រះអាជ្ញាថ្នាក់តំបន់ការពារសិទ្ធិបោះឆ្នោតរបស់ជនពិការ។ CERMI ក៏បានតស៊ូមតិផងដែរជាមួយរដ្ឋាភិបាល និងសភា ឲ្យធ្វើវិសោធនកម្មច្បាប់ ឲ្យស្របតាមសេចក្តីសន្និដ្ឋានចុងក្រោយរបស់ CRPD។ សេចក្តីស្នើវិសោធនកម្ម ក៏ត្រូវបានបញ្ជូនទៅសមាជិកសភា និងរដ្ឋាភិបាល។

តួអង្គសង្គមស៊ីវិល អាចប្រើសម្លេងសហគមន៍អន្តរជាតិ ដើម្បីគាំទ្រយុទ្ធសាស្ត្រជាតិក្នុងការប្រមែប្រមូលប្រជាជនក្នុងស្រុក ព្រមទាំងលើកទឹកចិត្តដល់មន្ត្រីសាធារណៈឲ្យលើកកម្ពស់ និងការពារលំហសង្គមស៊ីវិល។

## តើខ្ញុំអាចធ្វើអ្វីខ្លះបាន?

- ត្រូវយល់ដឹង និងចែករំលែកឯកសារសិទ្ធិមនុស្សអង្គការសហប្រជាជាតិដែលទាក់ទងនឹងប្រទេសរបស់អ្នក៖

**http://www.ohchr.org/EN/Countries/Pages/HumanRightsintheWorld.aspx**

- ទាក់ទងការិយាល័យ OHCHR ដែលនៅជិតបំផុត ឬក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ និងចែករំលែករបាយការណ៍របស់អ្នកស្តីពីបទពិសោធន៍របស់អ្នកអំពីលំហសង្គមស៊ីវិល ជាមួយផ្នែកសង្គមស៊ីវិលរបស់ OHCHR: **civilsociety@ohchr.org**

- ស្វែងយល់ពីរបៀបរួមចំណែក និងចូលរួមក្នុងការងាររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស៖

**http://www.ohchr.org/Documents/Publications/NgoHandbook/ngohandbook4.pdf**

- បញ្ជូនពាក្យបណ្តឹងស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្ស រួមទាំងសំណើសុំវិធានការបណ្តោះអាសន្ន ឬវិធានការបន្ទាន់ក្នុងករណីសមស្រប៖

http://www.ohchr.org/Documents/Publications/FactSheet7Rev.2.pdf

- បញ្ជូនពាក្យបណ្តឹងទៅកាន់អ្នកជំនាញនៃនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

http://www.ohchr.org/EN/HRBodies/SP/Pages/Communications.aspx

- បញ្ជូនពាក្យបណ្តឹងទៅកាន់នីតិវិធីបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

http://www.ohchr.org/EN/HRBodies/HRC/ComplaintProcedure/Pages/HRCComplaintProcedureIndex.aspx

- ចែករំលែកព័ត៌មាន និងបទពិសោធន៍ទាក់ទងនឹងលំហសង្គមស៊ីវិលនៅកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

http://www.ohchr.org/Documents/HRBodies/HRCouncil/PracticalGuideNGO_en.pdf

- ចែករំលែកព័ត៌មាន និងបទពិសោធន៍ទាក់ទង់នឹងលំហសង្គមស៊ីវិលនៅក្នុងការពិនិត្យរបាយការណ៍ឡើងវិញតាមពេលកំណត់ជាសកលរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សទៅលើប្រទេសអ្នក

**http://www.ohchr.org/EN/HRBodies/UPR/Documents/PracticalGuideCivilSociety.pdf**

- ផ្តល់ព័ត៌មានលម្អិត និងដែលបានបញ្ជាក់ថាពិត អំពីករណីដែលបានអះអាងអំពីការយាយី ការបំភិតបំភ័យ ឬការសងសឹកលើបុគ្គល ឬក្រុមណាមួយ ដោយសារតែសហការជាមួយអង្គការសហប្រជាជាតិ អ្នកតំណាង និងយន្តការអង្គការសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្ស ជាការរួមចំណែកមួយដល់របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការស្តីពីការសងសឹក៖ **reprisals@ohchr.org**
- ផ្តល់ធាតុចូលលើរបាយការណ៍តាមប្រធានបទរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬឧត្តមស្នងការសិទ្ធិមនុស្ស។
- ផ្តល់ធាតុចូលលើរបាយការណ៍របស់នីតិវិធីពិសេសតាមប្រធានបទ និងប្រចាំប្រទេស៖

http://www.ohchr.org/Documents/Publications/NgoHandbook/ngohandbook6.pdf

- ជាវបញ្ជីអ៊ីមែលរបស់ផ្នែកសង្គមស៊ីវិល ដើម្បីទទួលបានព័ត៌មានអំពីសកម្មភាពរបស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖

http://www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

## ការគ្រប់គ្រងការរំពឹងទុក

រដ្ឋ មានការទទួលត្រូវចម្បងក្នុងការលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ ខាងសមាគម ខាងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ។ តួអង្គសង្គមស៊ីវិល រួមជាមួយប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងតួអង្គដទៃទៀត អាចជួយរដ្ឋបំពេញកាតព្វកិច្ចទាំងនេះ។

ការដោះស្រាយឧបសគ្គចំពោះលំហសង្គមស៊ីវិល ដោយផ្អែកលើវិធាន ឬច្បាប់ ជាធម្មតា ទាមទារឲ្យមានក្របខណ្ឌពេលវេលាវែងឆ្ងាយ ដើម្បីធ្វើឲ្យការផ្លាស់ប្តូរមានប្រសិទ្ធភាព ខណៈដែលសកម្មភាពនានា ដូចជា ការយាយីការបំភិតបំភ័យ និងការសងសឹកលើតួអង្គសង្គមស៊ីវិល តម្រូវឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ វាជាការសំខាន់ក្នុងការប្រើប្រាស់អាណត្តិ ឬយន្តការរបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធស្របតាមករណីដែលមានបញ្ហា។

លទ្ធភាព ក្នុងការធ្វើឲ្យមានឥទ្ធិពលទៅលើលទ្ធផលប្រកបដោយវិជ្ជមាននៅក្នុងស្ថានភាពណាមួយក្តី គឺកិច្ចខិតខំប្រឹងប្រែងរួមគ្នា ហើយជាធម្មតា នឹងត្រូវបានកំណត់ដោយការកៀងគរតួអង្គឲ្យបានច្រើន៖ សាធារណជនក្នុងស្រុក តួអង្គសង្គមស៊ីវិលដទៃទៀត (ក្នុងប្រទេស និងក្រៅប្រទេស) ស្ថាប័នសិទ្ធិមនុស្សជាតិ ប្រព័ន្ធផ្សព្វផ្សាយ មន្ត្រីសាធារណៈ អ្នកនយោបាយ ប្រទេសផ្សេងៗទៀត និងសហគមន៍ថ្នាក់តំបន់ និងអន្តរជាតិ។

ការចូលរួមជាមួយប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិពីសំណាក់តួអង្គសង្គមស៊ីវិល គឺជាមធ្យោបាយមួយដើម្បីបង្កើន និងបន្ទរសម្លេងនៃការផ្លាស់ប្តូរ។ វាគឺជាធាតុផ្សំមួយនៃយុទ្ធសាស្ត្រតស៊ូមតិជារួម ប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ និងការពារលំហសង្គមស៊ីវិល។



# ៦. ធនធានឯកសារ

## ប្រភពអង្គការសហប្រជាជាតិ

Working with the United Nations Human Rights Programme: A Handbook for Civil Society -

**http://www.ohchr.org/EN/AboutUs/CivilSociety/Documents/Handbook_en.pdf**

How to Follow Up on United Nations Human Rights Recommendations - A Practical Guide for Civil Society -

**http://www.ohchr.org/Documents/AboutUs/CivilSociety/HowtoFollowUNHRRecommendations.pdf**

OHCHR Management Plan (2014-2017), Thematic Strategy on Widening the Democratic Space (pp. 72-83) -

**http://www2.ohchr.org/english/OHCHRreport2014_2017/OMP_Web_version/media/pdf/10_Democratic_space.pdf**

Declaration on Human Rights Defenders -

**http://www.ohchr.org/EN/Issues/SRHRDefenders/Pages/Declaration.aspx**

Summary of the Human Rights Council panel discussion on the importance of the promotion and protection of civil society space, A/HRC/27/33.

Human Rights Committee, General Comment No. 34, Article 19: Freedoms of opinion and expression, CCPR/C/GC/34.

An assessment of legislation relating to freedom of association, Report of the Special Rapporteur on the situation of human rights defenders, A/64/226.

A study on women human rights defenders, Report of the Special Rapporteur on the situation of human rights defenders, A/HRC/16/44.

Elements of a safe and enabling environment for human rights defenders, Report of the Special Rapporteur on the situation of human rights defenders, A/HRC/25/55.

Ability of associations to access financial resources, Report of the Special Rapporteur on the rights to freedom of peaceful assembly and of association, A/HRC/23/39.

Reports of the Secretary-General on cooperation with the United Nations, its representatives and mechanisms in the field of human rights (A/HRC/27/38, A/HRC/24/29, A/HRC/21/18, A/HRC/18/19, A/HRC/14/19)

Chapter 16, Engagement and Partnerships with Civil Society, OHCHR Manual on Human Rights Monitoring -

http://www.ohchr.org/Documents/Publications/Chapter16-MHRM.pdf

### ប្រភពពីសង្គមស៊ីវិលមួយចំនួន និងប្រភពដទៃទៀត

បញ្ជីផ្ទៀងផ្ទាត់នៃគោលការណ៍ និងធាតុផ្សំនៃច្បាប់ជាតិ (មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនគិតកម្រៃ)

http://www.icnl.org/research/library/files/Transnational/checklisten.pdf

Code of Good Practice for civil society participation modalities in decision-making processes, Council of Europe -

http://www.coe.int/t/ngo/code_good_prac_en.asp

Reprisals Handbook (International Service for Human Rights) -

http://www.ishr.ch/news/reprisals-handbook

Enabling Environment Index 2013 (CIVICUS) -

http://www.civicus.org/downloads/2013EEI%20REPORT.pdf

## ៧. ទាក់ទងជាមួយយើងខ្ញុំ

**ផ្នែកសង្គមស៊ីវិលរបស់** OHCHR **អាចទំនាក់ទំនងតាមអាសយដ្ឋានខាងក្រោម៖**

civilsociety@ohchr.org

**ទូរសព្ទ៖** +41 (0) 22 917 9656

ប្រព័ន្ធផ្សាយតាមអ៊ីមែលរបស់សង្គមស៊ីវិល ផ្តល់ព័ត៌មានបច្ចុប្បន្នភាព និងការណែនាំអំពីអាណត្តិនិងយន្តការសិទ្ធិមនុស្សទាំងអស់ ក៏ដូចជា ព័ត៌មាន និងកាលបរិច្ឆេទនៃការដាក់ពាក្យសុំមូលនិធិជំនួយឥតសំណង និងអាហារូបករណ៍។

ដើម្បីជាវ សូមចូលមើលគេហទំព័រសង្គមស៊ីវិល

http://www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx



Made of paper awarded the European Union Eco-label, reg.nr FI/111/, supplied by UPM.

មគ្គុទ្ទេសក៍ជាក់ស្តែងសម្រាប់សង្គមស៊ីវិល

លំហសង្គមស៊ីវិល និងប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

**Office of the High Commissioner for Human Rights**

Palais des Nations
CH 1211 Geneva 10- Switzerland
Telephone: + 41 (0)22 917 90 00
Fax: +41 (0) 22 917 90 08
www.ohchr.org

UNITED NATIONS

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia